FACT Sustainable Livelihoods

CRITICAL ECOSYSTEM PARTNERSHIP FUND

# ទស្សនៈផ្ទុយគ្នាអំពីការលិចទឹក
# របាយការណ៍ស្ដីពីបទពិសោធន៍របស់សហគមន៍ ដែលត្រូវតាំងទីលំនៅថ្មីសម្រាប់គម្រោងទំនប់ វារីអគ្គិសនីទន្លេសេសានក្រោម ២





## លទ្ធផល និងអនុសាសន៍ទៅលើដំណើរការ នៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ



TONLE SAP LAKE WATERKEEPER®

សម្ព័ន្ធប្រជានេសាទកម្ពុជា
The Coalition of Cambodia Fishers (CCF)

អង្គការភូមិខ្ញុំ
MY VILLAGE

3S Rivers Protection Network

CEPA Culture and Environment Preservation Association

ខែកក្កដា ឆ្នាំ២០១៦

# ទស្សនៈផ្ទុយគ្នាអំពីការលិចទឹក
# របាយការណ៍ស្តីពីបទពិសោធន៍របស់សហគមន៍ដែលត្រូវតាំងទីលំនៅថ្មីសម្រាប់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២៖ លទ្ធផល និងអនុសាសន៍ទៅលើដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ

រៀបរៀងដោយ៖ អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)

គាំទ្រថវិកាដោយ៖ CEPF

ខែកក្កដា ឆ្នាំ២០១៦

# ទស្សនៈផ្ទុយគ្នាអំពីការលិចទឹក
# របាយការណ៍ស្តីពីបទពិសោធន៍របស់សហគមន៍ដែលត្រូវតាំងទីលំនៅថ្មីសម្រាប់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២៖ លទ្ធផលនិងអនុសាសន៍ទៅលើដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ


ប្រមូលទិន្នន័យដោយ៖ សហគមន៍ភូមិក្បាលរមាស និងសហគមន៍ភូមិស្រែគរ

គាំទ្រថវិកា និងបច្ចេកទេស និងរៀបរៀងជារបាយការណ៍ដោយ៖

អង្គការភូមិខ្ញុំ (MVi) អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង (3SPN) សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) អង្គការឃ្លាំមើលទន្លេមេគង្គ (Mekong Watch) និងអង្គការអឺសរ៉ៃត្សន៍អន្តរជាតិ (EarthRights International)

បោះពុម្ពផ្សាយដោយ៖ អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)

ពិនិត្យ និងកែសម្រួលរបាយការណ៍ដោយ៖

១. លោក ឱម សាវ៉ាត — នាយកប្រតិបត្តិអង្គការ FACT

២. លោក យុក សេងឡុង — នាយកប្រតិបត្តិរងអង្គការ FACT និងជាអ្នកសម្របសម្រួលបណ្តាញអ្នកថែរក្សាទឹកបឹងទន្លេសាប

៣. លោក ហែម ឧត្តម — អ្នកប្រឹក្សាយោបល់ឯករាជ្យ

រចនាបថដោយ៖ លោក ហុង ដារ៉ែន មន្ត្រីព័ត៌មានវិទ្យា និងទំនាក់ទំនងនៃអង្គការ FACT

# មាតិកា


| | |
|---|---|
| I. សេចក្តីផ្តើម | 1 |
| II. ទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២ | 3 |
| III. ការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ | 5 |
| IV. លទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះ | 6 |
| ព័ត៌មានមិនគ្រប់គ្រាន់អំពីក្រុមចុះស្រង់ទិន្នន័យ និងគោលបំណង | 6 |
| ការពន្យល់មិនគ្រប់គ្រាន់អំពីដំណើរការនៃការស្រង់ទិន្នន័យ និងឯកសារ | 7 |
| ខ្វះការពិគ្រោះយោបល់ប្រកបដោយផ្លែផ្កា | 7 |
| កង្វះការយល់ដឹងអំពីដំណើរការនៃការស្រង់ទិន្នន័យ និងឯកសារស្រង់ទិន្នន័យ | 7 |
| ការចូលរួមច្រើនដោយគ្មានការយល់ដឹង និងយល់ព្រមច្បាស់លាស់ | 8 |
| ការខកខានក្នុងការផ្តល់ឯកសារ | 10 |
| ការខកខានក្នុងការបញ្ចូលសហគមន៍ទាំងអស់ដែលរងផលប៉ះពាល់ដោយសារគម្រោង | 10 |
| ការភ័យខ្លាចទឹកលិច និងគ្មានជម្រើស | 10 |
| អារម្មណ៍ខ្លាច ភិតភ័យ និងគាបសង្កត់អំឡុងពេលចុះស្រង់ទិន្នន័យទ្រព្យសម្បត្តិ | 12 |
| វត្តមានមន្ត្រីនគរបាល និងកង្វះចំណេះដឹងអំពីសិទ្ធិរបស់ពួកគាត់ | 13 |
| ក្រុមហ៊ុនសន្យា ប៉ុន្តែខ្វះការទុកចិត្ត | 14 |
| ហេតុអ្វីបានជាប្រជាពលរដ្ឋជាច្រើនបដិសេធមិនចូលរួម | 16 |
| V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ | 17 |
| ឯកសារយោង | 20 |

# សេចក្តីថ្លែងអំណរគុណ

**អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល** (FACT) **អង្គការភូមិខ្ញុំ** (MVi) **អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង** (3SPN) និង **សមាគមថែរក្សាបរិស្ថាន និង វប្បធម៌** (CEPA) សូមថ្លែងអំណរអគុណយ៉ាងជ្រាវជ្រៅ ដល់ប្រធានភូមិ និងប្រជាពលរដ្ឋនៅក្នុងភូមិក្បាលរមាស ស្រែស្រណុក ភូមិច្រប់ ភូមិស្រែគរ១ និង ភូមិស្រែគរ២ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងខិតខំប្រឹងប្រែងដើម្បីចូលរួមក្នុងដំណើរការ សិក្សាស្រាវជ្រាវស្វែងរកការពិតនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះសហគមន៍ក្បាលរមាស និងសហគមន៍ស្រែគរ ដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការចុះប្រមូលទិន្នន័យនៅក្នុងតំបន់សិក្សាស្រាវជ្រាវដែលបាន រៀបរាប់ខាងលើ។ ប្រសិនបើគ្មានការគ្រាំទ្រ ការចូលរួមយ៉ាងសកម្ម និងការចូលរួមចំណែកពីសហគមន៍ ទាំងនេះទេ នោះលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងមិនអាចលេចចេញជារូបរាងបានឡើយ។

លើសពីនេះទៅទៀត យើងខ្ញុំក៏សូមសម្តែងនូវការកោតសរសើរដល់បុគ្គលិកអង្គការ FACT, MVi, 3SPN, និង CEPA ទីប្រឹក្សាឯករាជ្យ និងអ្នកជំនាញផ្សេងៗទៀត ដែលបានចូលរួមតាមរយៈ ការពិគ្រោះយោបល់ និងបានចូលរួមបញ្ចប់របាយការណ៍ស្វែងរកការពិតនេះ។

ជាចុងក្រោយ យើងខ្ញុំក៏សូមថ្លែងនូវការដឹងគុណដល់ លោក **ឱម សាវ៉ាត**នាយកប្រតិបត្តិអង្គការ FACT លោក **យុគ សេងឡុង** នាយកប្រតិបត្តិរងអង្គការ FACT និងជាអ្នកសម្របសម្រួល បណ្តាញអ្នកថែរក្សាទឹកបឹងទន្លេសាប(TSW) និងលោក **ហែម ឧត្តម** អ្នកប្រឹក្សាយោបល់ឯករាជ្យ ដែលបានត្រួតពិនិត្យ និងកែសម្រួលនូវរបាយការណ៍នេះ ដើម្បីឲ្យមានអត្ថន័យគ្រប់គ្រាន់។

## សេចក្តីបញ្ជាក់:

ទស្សនៈដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ មិនបានបង្ហាញពីទស្សនៈរបស់**អង្គការសម្ព័ន្ធភាព ដើម្បីអភិរក្សធនធានជលផល** (FACT) **អង្គការភូមិខ្ញុំ** (MVi) **អង្គការបណ្តាញការពារ ទន្លេសេសាន ស្រែពក សេកុង** (3SPN) និង**សមាគមថែរក្សាបរិស្ថាន និង វប្បធម៌** (CEPA)។

## I.សេចក្តីផ្តើម

នៅចុងឆ្នាំ២០១៤មន្រ្តីមកពីគណៈកម្មការតាំងទីលំនៅថ្មីសម្រាប់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ (LS2) នេះ បានមកដល់ភូមិ ដែលស្ថិតនៅក្នុងតំបន់អាងនៃទំនប់សេសានក្រោម២ នៅក្នុងខេត្តស្ទឹងត្រែងភាគឦសាននៃប្រទេសកម្ពុជា ហើយបានចាប់ផ្តើមចងក្រងឯកសារស្តីពីទ្រព្យសម្បត្តិរបស់សហគមន៍ក្នុងការរៀបចំសម្រាប់សំណើផ្លាស់ប្តូរទីតាំង ដើម្បីបើកផ្លូវសម្រាប់សាងសង់ទំនប់វារីអគ្គិសនីនេះ។ មានសេចក្តីរាយការណ៍ភ្លាមៗពីភូមិ អំពីភាពមិនប្រក្រតីដែលពាក់ព័ន្ធនឹងដំណើរការនេះ។ មានអ្នកភូមិជាច្រើនបានចូលរួមបំពេញសំណួរស្រង់ទិន្នន័យនេះដោយពុំបានយល់អំពីគោលបំណងនៃដំណើរការនេះឡើយ អ្នកភូមិខ្លះទៀតពុំទទួលបានព័ត៌មានអំពីគោលនយោបាយតាំងទីលំនៅថ្មី និងការផ្តល់សំណងទេ ឬពួកគាត់ត្រូវគេដាក់គំនាប និងបំភិតបំភ័យឲ្យផ្តិតមេដៃលើសំណុំឯកសារស្រង់ទិន្នន័យនោះ។ មានបងប្អូនប្រជាពលរដ្ឋជាច្រើនគ្រួសារបានបដិសេធមិនចូលរួមក្នុងការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនោះទេ ផ្ទុយទៅវិញ ពួកគាត់បានអះអាងអំពីការជំទាស់របស់ខ្លួនទៅនឹងការសាងសង់ទំនប់វារីអគ្គិសនីនេះ។

របាយការណ៍នេះត្រូវបានធ្វើឡើងដោយផ្អែកលើការស្រាវជ្រាវជាបន្តបន្ទាប់នៅតាមភូមិចំនួន៤ ក្នុងគោលបំណងដើម្បីស្វែងរកឲ្យឃើញបន្ថែមទៀត អំពីបទពិសោធន៍របស់អ្នកភូមិដែលបានដឹងក្នុងអំឡុងពេលដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ និងស្វែងយល់ថា តើបញ្ហានេះរារីករាលដាលយ៉ាងដូចម្តេច។

ទម្រង់បញ្ជីសំណួរជាង ២២០ ត្រូវបានបំពេញ នៅភូមិក្បាលរមាស ស្រែស្រណុក ច្រប់ និងភូមិស្រែគរ១ និងភូមិស្រែគរ២[1] ពីខែកក្កដារហូតដល់ខែសីហា ឆ្នាំ២០១៥។[2] ការជួបសម្ភាសយ៉ាងលម្អិតជាច្រើនក៏ត្រូវបានធ្វើឡើងដែរ ដែលការសម្ភាសលម្អិតនេះត្រូវបានធ្វើជាមួយសមាជិកសហគមន៍ភូមិភ្លុក ដែលប្រជាពលរដ្ឋនឹងប្រឈមការបាត់បង់ដី ឬប្រជាពលរដ្ឋដែលបានបាត់បង់ដីធ្លីរួចហើយដោយសារ គម្រោងនេះ ប៉ុន្តែមិនត្រូវបានបញ្ចូលទៅក្នុងទម្រង់ស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនេះទេ ហើយទ្រព្យសម្បត្តិរបស់ពួកគាត់មិនទាន់ត្រូវបានវាយតម្លៃសម្រាប់ការផ្តល់សំណងនៅឡើយ។[3]

ទោះបីជាការសិក្សាស្រាវជ្រាវនេះនៅមានកម្រិត ដោយសារតែទំហំនៃសំណាក និងផលលំបាកផ្សេងទៀតក៏ដោយ ក៏លទ្ធផលរកឃើញពីការស្រាវជ្រាវនេះ បានបង្ហាញថា ដំណើរការនៃការចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិបានបំពានលិខិតបទដ្ឋានជាតិនិងអន្តរជាតិស្តីពីការតាំងទីលំនៅថ្មី

---

1 ក្នុងការវិភាគនេះ ភូមិស្រែគរ១និងស្រែគរ២ ត្រូវបានចាត់ទុកជាសហគមន៍តែមួយ។ នៅក្នុងកំណត់ហេតុផ្សេងៗទៀត ជួនកាលគេចាត់ទុកថាជាភូមិពីរដាច់ដោយឡែកពីគ្នា។

2 កម្រងបញ្ជីរសំណួរដែលមាន២២២បញ្ជីរសំណួរត្រូវបានបំពេញនៅទូទាំងសហគមន៍ មានភូមិក្បាលរមាស ភូមិស្រែស្រណុក ភូមិច្រប និងភូមិស្រែគរ។ អ្នកឆ្លើយបញ្ជីរសំណួរ៦៦%ជាស្ត្រី និង៣៤% ជាបុរស ដែលមានអាយុចាប់ពី១៨ ដល់៨០ឆ្នាំ។ យើងបានសួរអ្នកចូលរួមឆ្លើយបញ្ជីរសំណួរទាំងអស់នូវបញ្ជីរសំណួរជាបន្តបន្ទាប់អំពីបទពិសោធរបស់ពួកគាត់នៅពេលក្រុមចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ហើយយើងក៏បានផ្តល់ឱកាសជូនពួកគាត់ផ្តល់យោបល់ដែលពួកគាត់ចង់បន្ថែមដែរ។

3 កំណត់ចំណាំក្រៅផ្លូវការពីកិច្ចសម្ភាសន៍ជាមួយអ្នកភូមិដែលទទួលរងផលប៉ះពាល់ នៅភូមិភ្លុក ដោយអង្គការឃ្លាំមើលទន្លេមេគង្គ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។

និងការផ្តល់សំណង ព្រមទាំងបានរំលោភលើសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ ដោយសារទំនប់វារីអគ្គិសនីនេះ។ [4]ការព្រួយបារម្ភចម្បងៗដែលបានរកឃើញក្នុងអំឡុងពេលដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនោះ មានដូចជា កង្វះការជូនដំណឹងជាមុន ការខកខានមិនបានផ្សព្វផ្សាយព័ត៌មាន ការមិនបានពិគ្រោះយោបល់ត្រឹមត្រូវជាមួយអ្នកដែលត្រូវតាំងទីលំនៅថ្មី ការគំរាមកំហែង និងការបំភិតបំភ័យដើម្បីទទួលបានការយល់ព្រមទៅតាមក្រុមចុះស្រង់ទិន្នន័យ និងអំពីគោលនយោបាយស្តីពីការផ្តល់សំណង និងការតាំងទីលំនៅថ្មី។ ដោយផ្អែកលើលទ្ធផលពីការរកឃើញទាំងនេះ របាយការណ៍នេះបានសន្និដ្ឋានថា លទ្ធផលនៃការចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ គប្បីត្រូវចាត់ទុកជាមោឃៈ។ មានការផ្តល់ជាយោបល់ថាគួរមានការស៊ើបអង្កេតមួយពាក់ព័ន្ធនឹងបញ្ហានេះ ហើយដំណើរការនៃការស្រង់ទិន្នន័យទ្រព្យសម្បត្តិនេះគប្បីត្រូវធ្វើឡើងវិញ ដើម្បីធានាដល់ការគោរពពេញលេញនូវគោលការណ៍ច្បាប់កម្ពុជា និងស្តង់ដារអនុវត្តប្រសើរបំផុតរបស់អន្តរជាតិ និងការគោរពសិទ្ធិរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់។

*"ខ្ញុំយល់ព្រម ព្រោះក្រុមចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិបានប្រាប់ថា គេនឹងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២។ គេនិយាយថា ប្រសិនបើខ្ញុំមិនព្រមឥឡូវនេះទេ នោះផ្ទះរបស់ខ្ញុំនឹងត្រូវទឹកលិច ហើយគេនឹងមិនទទួលខុសត្រូវចំពោះការខូចខាតណាមួយឡើយ។ ខ្ញុំមិនយល់ឯកសារនោះទេ ប៉ុន្តែខ្ញុំបានឃើញអ្នកភូមិដទៃទៀតផ្តិតមេដៃ ខ្ញុំក៏ផ្តិតដែរទៅ"។*

**ស្ត្រីអាយុ៥៤ឆ្នាំ នៅភូមិស្រែស្រណុក ខែកក្កដា ឆ្នាំ២០១៥**

*"គេនិយាយថា គេនឹងផ្តល់ផ្ទះថ្មីមួយឱ្យយើង និងថានៅពេលដែលការសាងសង់រួចរាល់យើងអាចរើទៅនៅទីនោះបាន។ គេក៏បានសន្យាផ្តល់សំណងសមរម្យឲ្យយើងដែរ និងថា ដោះស្រាយអ្វីគ្រប់យ៉ាងឲ្យយើង។ គេនិយាយថា គេនឹងសងដី ផលដំណាំ ក្រោលគោរហូតដល់ទ្រុងមាន់ និងទ្រុងទាទៀត។ គេនិយាយថា ប្រសិនបើខ្ញុំមិនព្រមចាកចេញទេ ខ្ញុំនឹងមិនបានអ្វីទាំងអស់។ យើងខ្លាចបាត់បង់ដីរបស់យើង ដូច្នេះយើងយល់ព្រមតាមក្រុមចុះស្រង់ទិន្នន័យ"។*

**គ្រួសារដែលមានសមាជិក៣នាក់ នៅភូមិស្រែគរ ខែកក្កដា ឆ្នាំ២០១៥**

---

4 នៅថ្នាក់ជាតិ លិខិតបទដ្ឋានទាំងនេះ មានបញ្ចូលនូវបណ្តាមាត្រាដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៣៥, ៤៤), ច្បាប់ភូមិបាលឆ្នាំ២០០១ (មាត្រា៤, ៥) និងច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០។ម្យ៉ាងទៀត ច្បាប់កិច្ចសន្យារបស់កម្ពុជា ហាមប្រាមការរៀបចំកិច្ចសន្យាដែលមិនបានមកពីកិច្ចព្រមព្រៀងពិតប្រាកដ និងដោយគ្មានការបង្ខិតបង្ខំ ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ឬប្រើការបង្ខិតបង្ខំ ឬការបកស្រាយខុសដើម្បីទទួលបានកិច្ចព្រម (ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ផ្នែកទី២ មាត្រា ៣៤៥-៣៥០)។ រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចតាមផ្លូវច្បាប់ដែលត្រូវគោរពសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស រួមទាំងកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ គោលការណ៍ណែនាំឆ្នាំ១៩៦៦ សម្រាប់ការអនុវត្តតាមលិខិតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងការអភិវឌ្ឍដែលបណ្តាលឲ្យមានការតាំងទីលំនៅថ្មី ត្រូវបានកំណត់នៅក្នុង "គោលការណ៍ជាមូលដ្ឋាននិងគោលការណ៍ណែនាំស្តីពីការបណ្តេញនិងការផ្លាស់ប្តូរទីតាំងរស់នៅដោយផ្អែកលើគម្រោងអភិវឌ្ឍន៍" របស់អង្គការសហប្រជាជាតិឆ្នាំ១៩៩៧ (ឧបសម្ព័ន្ធ ឯកសាររបស់ អង្គការសហប្រជាជាតិលេខ UN Doc E/CN.4/Sub.2/1997/7)។

*"ខ្ញុំមិនចង់បានសំណង ហើយខ្ញុំមិនអាចចាកចេញពីភូមិ និងផ្ទះដូនតារបស់ខ្ញុំទេ។ ការតាំងទីលំនៅថ្មីនឹងធ្វើឱ្យយើងបាត់បង់ផ្ទះ និងផលដំណាំរបស់យើង ទន្លេសម្រាប់នេសាទត្រី បាត់បង់មុខរបរ និងប្រាក់ចំណូល។ គេនិយាយថា ប្រសិនបើខ្ញុំមិនចូលរួមជាមួយការស្រង់ទិន្នន័យនៅថ្ងៃនោះទេ គេមិនធ្វើអ្វីៗឲ្យយើងទេនៅពេលអនាគត។ ខ្ញុំត្រូវគេគំរាមកំហែង ប៉ុន្តែខ្ញុំដឹងថា ប្រសិនបើ ខ្ញុំផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យនោះ ខ្ញុំនឹងបាត់បង់សិទ្ធិរបស់ខ្ញុំ ហើយខ្ញុំនឹងមិនរុះរើទេ"។*

**បុរសអាយុ៧២ឆ្នាំ នៅភូមិច្រប់ ខែកក្កដា ឆ្នាំ២០១៥**

*"ខ្ញុំស្រឡាញ់ភូមិចាស់របស់ខ្ញុំ និងមិនអាចចាកចេញពីដីបញ្ចុះសពបុព្វបុរសរបស់ខ្ញុំទេ។ នៅពេលដែលខ្ញុំបដិសេធមិនផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យនោះ អាជ្ញាធរព្រមានខ្ញុំឲ្យខ្ញុំគោរពថ្នាក់លើរបស់គេ ពេលនោះខ្ញុំមានអារម្មណ៍ថា ត្រូវគេបំភិតបំភ័យ និងដាក់សម្ពាធលើខ្ញុំ ប៉ុន្តែខ្ញុំមិនបានចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យនោះទេ។ ខ្ញុំបានអំពាវនាវឲ្យក្រុមហ៊ុនបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនីនេះ។ យើងមិនត្រូវការវាទេ"។*

**ស្ត្រីអាយុ៥៥ ឆ្នាំ នៅភូមិស្រែសគរ**

## II. ទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២

ទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២គឺជាទំនប់ដែលមានកម្ពស់៧៥ម៉ែត្រ កម្លាំង៤០០មេហ្គាវ៉ាត់ស្ថិតនៅតាមដងទន្លេសេសានក្នុងខេត្តស្ទឹងត្រែង ភាគឦសាននៃប្រទេសកម្ពុជា មានចម្ងាយ២៥គីឡូម៉ែត្រនៅផ្នែកខាងលើពីកន្លែងដែលទន្លេនេះតភ្ជាប់ជាមួយទន្លេមេគង្គ។ គម្រោងដែលត្រូវចំណាយទឹកប្រាក់ ៨១៦ លានដុល្លារអាមេរិកត្រូវបានរៀបចំអភិវឌ្ឍន៍ដោយក្រុមហ៊ុនវារីអគ្គិសនីទន្លេសេសានក្រោម២ ដែលជាក្រុមហ៊ុនរួមទុនរវាងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប (Royal Group) របស់ប្រទេសកម្ពុជា និងក្រុមហ៊ុន Hydrolancang International Energy Limited របស់ប្រទេសចិន និងក្រុមហ៊ុនភាគហ៊ុនអន្តរជាតិ EVN របស់ប្រទេសវៀតណាម។ [5]







***រូបភាពទី ១ ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២***

5 www.internationalrivers.org/campaigns/lower-sesan-2-dam

www.mekongwatch.org/PDF/LS2_NotesCompensationResettlement.pdf

ទំនប់វារីអគ្គិសនីនេះត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីរបស់ប្រទេសកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ២០១២ ទោះបីជា មានការរិះគន់យ៉ាងខ្លាំងៗថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងនេះ មិនបានបំពេញតាមបទដ្ឋាននៃការអនុវត្តល្អបំផុតជាអន្តរជាតិ ដែលក្នុងនោះពុំមាន ការពិគ្រោះយោបល់ គ្រប់គ្រាន់ជាមួយអ្នកភូមិដែលរងការប៉ះពាល់ដោយសារគម្រោងឡើយ។[6] ការសាងសង់បានចាប់ផ្តើម នៅដើមឆ្នាំ២០១៤ ហើយទោះបីជាត្រូវបានផ្អាកមួយរយៈខ្លីក្នុងខែវិច្ឆិកាឆ្នាំដដែលនោះដោយ សារតែមានក្តីបារម្ភខាងបរិស្ថាន និងមានការដាក់សម្ពាធពីក្រុមសហគមន៍មូលដ្ឋាន និងអង្គការមិនមែន រដ្ឋាភិបាលក៏ដោយ ក៏ការសាងសង់នេះ ត្រូវចាប់ផ្តើមឡើងវិញនៅខែមីនា ឆ្នាំ២០១៥ ហើយគេជឿថា ឥឡូវការសាងសង់ទំនប់នេះត្រូវបានបញ្ចប់៤០%ហើយ។[7]

យោងតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការតាំងទីលំនៅថ្មី គប្បីត្រូវប្រព្រឹត្ត ទៅ " ... *ដោយអនុលោមទៅតាមផែនការគ្រប់គ្រងការផ្លាស់ប្តូរទីលំនៅ រីឯដី និងហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវផ្តល់ឲ្យត្រូវតែ មានលក្ខណៈដូចដី និងហេដ្ឋារចនាសម្ព័ន្ធចាស់របស់អ្នកភូមិដែលត្រូវទៅតាំង ទីលំនៅថ្មីនោះដែរ ប្រសិនបើទីតាំងថ្មីនោះមិនមានលក្ខណៈល្អប្រសើរជាងទីតាំងចាស់ទេ។ ត្រូវមាន ការផ្តល់សំណងតាមរយៈការចរចារជាមួយភូមិដែលទទួលរងផលប៉ះពាល់ ហើយក៏ត្រូវអនុវត្តតាម ផែនការក្របខណ្ឌនៃការតាំងលំនៅថ្មី ដែលអនុម័តដោយ IRC / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាក់ព័ន្ធ*" ដែរ។[8]

តាមការប៉ាន់ស្មានជាផ្លូវការបញ្ជាក់ថា គម្រោងទំនប់នេះនឹងធ្វើឲ្យប្រជាជនប្រមាណ៥០០០ នាក់បាត់បង់ដីធ្លី និងទីលំនៅ រួមទាំងក្រុមជនជាតិដើម និងជនជាតិភាគតិចដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅ របស់ពួកគាត់ និងត្រូវទៅរស់នៅតាំងថ្មី ដើម្បីយកដីសម្រាប់សាងសង់អាងទំហំ៣៣.៥៦០ហិចតា។[9] ទោះជាយ៉ាងនេះក្តី តួលេខនៃប្រជាសហគមន៍ដែលទទួលរងផលប៉ះពាល់ និងត្រូវបាត់បង់ដីធ្លី និង លំនៅដ្ឋានដោយសារគម្រោងនេះ ទំនងជាមានច្រើនជាងតួលេខផ្លូវការនេះ ដោយរាប់បញ្ចូលមិន ត្រឹមតែអ្នកនៅក្នុងតំបន់អាងនោះទេ ប៉ុន្តែត្រូវរាប់បញ្ចូលប្រជាសហគមន៍នៅខ្សែទឹកខាងលើ និង ខាងក្រោមដែលនឹងត្រូវបាត់បង់ទីកន្លែងដែលជា ប្រ ភ ពស្បៀងអាហារ និងរបរចិញ្ចឹមជីវិត ដែលអ្នក ខ្លះត្រូវបង្ខំឱ្យចាកចេញពីលំនៅដ្ឋានរបស់ពួកគាត់។ កញ្ចប់សំណង និងការតាំងលំនៅថ្មីមិនដោះស្រាយ ផលប៉ះពាល់របស់សហគមន៍ទាំងនេះទេ។[10]

6 www.internationalrivers.org/resources/proposed-lower-sesan-2-dam-cambodia-fails-to-uphold-best-practice-3787

7 www.mekongcommons.org/lower-sesan-2-construction-resumed-troubles-restarted

8 ឯកសាររបស់ ក្រុមហ៊ុនប្រឹក្សាយោបល់គន្លឹះ (កម្ពុជា) អិលធីឌី ស្តីពី៖ "ការវាយតម្លៃផលប៉ះពាល់បរិស្ថាន សម្រាប់សិក្សាលទ្ធភាពវារីអគ្គីសនីទន្លេសេសានក្រោម២" ដោយក្រុមហ៊ុនប្រឹក្សាយោបល់គន្លឹះ (កម្ពុជា) អិលធីឌី (KCC), រាជធានីភ្នំពេញ, ខែតុលាឆ្នាំ 2008; ខ្លឹមសារសង្ខេប,ទំព័រ៦។

9 www.mekongwatch.org/PDF/LS2_NotesCompensationResettlement.pdf

10 របាយការណ៍នេះ មានគោលបំណងដើម្បីពិភាក្សាពីការខ្វះចន្លោះ នៅក្នុងការអនុវត្តនូវការសិក្សាវាយតម្លៃទ្រព្យសម្បត្តិដែលមានចែង នៅក្នុងផែនការសិក្សាវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងការផ្លាស់ប្តូរទីលំនៅបច្ចុប្បន្ន។ ការខ្វះចន្លោះនៅក្នុងការសិក្សាវាយតម្លៃពីហេតុប៉ះ ពា ល់ បរិស្ថាន និងផែនការផ្លាស់ប្តូរទីលំនៅសម្រាប់គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២នេះត្រូវបានគេលើកឡើង គ្រប់ទីកន្លែង។ ត្រ ង់ចំណុចនេះ របាយការណ៍នេះ ក៏ផ្តល់អនុសាសន៍ផងដែរថា ចំនួនប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីគម្រោង ទំនប់នេះ គួរ តែ មា ន ការគិតគូរថាមានច្រើនជាងចំនួនបច្ចុប្បន្ន ដោយរួមបញ្ចូលទាំងសហគមន៍នៅផ្នែកខាងលើ និងខាងក្រោមនៃទំនប់ ហើយប្រជាជនដែលទ ទួ លរងផលប៉ះពាល់ទាំងនោះ គួរតែទទួលបាននូវអ្វីគ្រប់គ្រាន់ រួមទាំងសិទ្ធិទទួលបាននូវការព្រមព្រៀងដោយសេរី ជាមុន និងមានព័ត៌មានគ្រប់គ្រាន់ (FPIC)។

## III. **ការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ**

ការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិជាផ្នែកយ៉ាងសំខាន់នៃដំណើរការផ្តល់សំណង និងការតាំងទីលំនៅ ថ្មីដែលគេប្រើសម្រាប់វាយតម្លៃ និងការចងក្រងឯកសារទ្រព្យសម្បត្តិរបស់គ្រប់គ្រួសារដែលរងផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនីនេះ។ ការវាយតម្លៃនេះ រួមទាំងការវាយតម្លៃអំពីផ្ទះ ដីធ្លី ដំណាំ ដើមឈើ និងសំណង់ផ្សេងៗទៀតរបស់គ្រួសារនីមួយៗ ដើម្បីគណនាចំនួនទឹកប្រាក់សមរម្យដែលត្រូវផ្តល់ជាសំណងដោយផ្អែកលើ "គោលការណ៍ផ្តល់សំណង និងការតាំងទីលំនៅថ្មី"។ នៅក្នុងករណីគម្រោងទំនប់វារីអគ្គិសនីទន្លេសេសានក្រោម២ ការទទួលខុសត្រូវចម្បងសម្រាប់អនុវត្តដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិគឺស្ថិតនៅលើគណៈកម្មការអន្តរក្រសួងកម្ពុជា ដែលទទួលបន្ទុកដោះស្រាយសំណង។

ក្នុងអំឡុងពីខែវិច្ឆិកាដល់ខែធ្នូ ឆ្នាំ២០១៤ គណៈកម្មការអន្តរក្រសួងកម្ពុជាដែលទទួលបន្ទុកដោះស្រាយសំណង បានចាប់ផ្តើមចុះអនុវត្តការងារស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ នៅក្នុងសហគមន៍ដែលត្រូវផ្លាស់ប្តូរទៅនៅទីតាំងថ្មី - មានភូមិក្បាលរមាស ស្រែស្រណុក ច្រប់ ភូមិស្រែគរ១និងភូមិស្រែគរ២។[11] មានប្រជាពលរដ្ឋជាច្រើនគ្រួសារបានជំទាស់យ៉ាងដាច់ខាតចំពោះគម្រោងនេះ ហើយបដិសេធមិនចូលរួមនៅក្នុងដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនេះទេ រីឯប្រជាពលរដ្ឋផ្សេងទៀតបានយល់ព្រមឲ្យវាស់ដីរបស់ពួកគាត់ ហើយបានផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យនេះ។ សេចក្តីរាយការណ៍ពីខាងក្នុងសហគមន៍បានធ្វើឲ្យលេចឮយ៉ាងរហ័សដល់បណ្តាអង្គការក្នុងស្រុកដែលទទួលបានដំណឹងថា អ្នកភូមិមិនទទួលបានព័ត៌មានគ្រប់គ្រាន់ទេ ព្រមទាំងត្រូវបានគំរាមកំហែង និងបំភិតបំភ័យឲ្យចូលរួមក្នុងដំណើរការស្រង់ទិន្នន័យ និងផ្តិតមេដៃលើឯកសារដោយផ្ទុយនឹងឆន្ទៈរបស់ពួកគាត់។

នៅក្នុងការរៀបរាប់មួយ ដែលកត់ត្រា និងចងក្រងដោយអង្គការឃ្លាំមើលទន្លេមេគង្គឲ្យដឹងថា អ្នកភូមិដែលមានអាយុ៥០ឆ្នាំជាងបានរៀបរាប់អំពីរបៀបដែលពួកគាត់ត្រូវគេប្រាប់ឱ្យផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យ ដោយមិនបានយល់ថា ហេតុអ្វីពួកគាត់ត្រូវធ្វើបែបនោះ និងមិនដឹងថា នឹងមានផលវិបាកអ្វីកើតឡើងពិតប្រាកដពីការផ្តិតមេដៃនោះឡើយ។ គាត់បាននិយាយថា "*ខ្ញុំបានសួរគេថា ហេតុអ្វីបានជាគេឲ្យយើងផ្តិតមេដៃក្នុងពេលស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិឥឡូវនេះ។ មន្ត្រីម្នាក់បានឆ្លើយថា គាត់ត្រូវការឲ្យខ្ញុំផ្តិតមេដៃពេលនេះ ប៉ុន្តែវាមិនមែនមានន័យថាយើងត្រូវតែរុះរើផ្ទះសម្បែងចេញនោះទេ។* គាត់និយាយថា នេះគឺគ្រាន់តែដើម្បីទទួលស្គាល់ប្រភេទទ្រព្យសម្បត្តិ ជាប្រភេទអ្វីដូចជាផ្ទះ ដើមឈើ និងដីឡូត៍ដែលយើងមាន។ ប៉ុន្តែក្រោយមក គេបានប្រើស្នាមមេដៃទាំងអស់នោះជាភស្តុតាងថា យើងបានព្រមព្រៀងទទួលសំណង និងផ្លាស់ប្តូរទៅតាំងទីលំនៅថ្មី"។[12]

ជាការឆ្លើយតបទៅនឹងរបាយការណ៍រីករាលដាលក្នុងករណីស្រដៀងគ្នានេះ ក្រុមសង្គមស៊ីវិល និងអ្នកស្រាវជ្រាវសហគមន៍ក្នុងមូលដ្ឋានបានវិលត្រឡប់ទៅសហគមន៍ជាថ្មី ដោយមានបញ្ជីសំណួរស្វែងរកការពិត ក្នុងគោលបំណងដើម្បីសិក្សាស្រាវជ្រាវស្រង់ព័ត៌មានពាក់ព័ន្ធនឹងបទពិសោធន៍របស់

---

11 ក្នុងការវិភាគនេះ ភូមិស្រែគរ១និងស្រែគរ២ ត្រូវបានចាត់ទុកជាសហគមន៍តែមួយ។ នៅក្នុងកំណត់ហេតុផ្សេងៗទៀត ជួនកាលគេចាត់ទុកថាជាភូមិពីរដាច់ដោយឡែកពីគ្នា។

12 www.mekongwatch.org/PDF/LS2_NotesCompensationResettlement.pdf

ពួកគាត់ អំពីការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនេះ និងដើម្បីប្រមូលព័ត៌មានបន្ថែមទៀត អំពីអ្វីដែលបានកើតឡើងក្នុងអំឡុងពេលនៃដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ។ ការសម្ភាសន៍ស៊ីជម្រៅជាច្រើនត្រូវបានធ្វើឡើង រួមទាំងសម្ភាសន៍ជាមួយអ្នកភូមិមកពីភូមិក្ដុកដែលគេមិនបានបញ្ចូលទៅក្នុងគោលនយោបាយតាំងទីលំនៅថ្មី និងសំណងផ្លូវការផង។[13]

## IV. លទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះ

របាយការណ៍នេះមានសេចក្ដីសង្ខេបអំពីលទ្ធផលសំខាន់ៗពីការស្រាវជ្រាវ និងមានអនុសាសន៍មួយចំនួនសម្រាប់ដោះស្រាយបញ្ហាដែលបានលើកឡើង។ ការរកឃើញដែលបានលើកឡើងក្នុងរបាយការណ៍នេះបង្ហាញឲ្យឃើញពីបញ្ហាដែលកើតឡើងជាប្រព័ន្ធទាក់ទងនឹងដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ដែលដំណើរការនេះត្រូវបានអនុវត្ត ដោយមិនសមរម្យ និងគ្មានតម្លាភាព បើផ្អែកលើការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់គម្រោង (ជាពិសេសផែនការគ្រប់គ្រងការផ្លាស់ប្ដូរទីលំនៅ) និងស្ដង់ដារអន្តរជាតិពាក់ព័ន្ធផ្សេងៗទៀត ដូចជាការអនុវត្តល្អជាលក្ខណៈអន្តរជាតិ។ ជាលទ្ធផល អាចមានអ្នកភូមិ រាប់ពាន់នាក់ដែលបានចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យដើម្បីកំណត់តម្លៃទ្រព្យសម្បត្តិរបស់ពួកគាត់ មិនបានផ្ដល់ការយល់ព្រមដោយសេរី គ្មានការបង្ខិតបង្ខំ និងដឹងព័ត៌មានច្បាស់លាស់អំពីដំណើរការនៃការស្រង់ទិន្នន័យនោះឡើយ។ នៅក្នុងកាលៈទេសៈបែបនេះ មានចំណោទសួរអំពីសុពលភាពនៃដំណើរការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនោះ។

## ព័ត៌មានមិនគ្រប់គ្រាន់អំពីក្រុមចុះស្រង់ទិន្នន័យ និងគោលបំណង

ព័ត៌មានដែលបានប្រមូលពីប្រជាពលរដ្ឋជាច្រើនគ្រួសារតាមរយៈកម្រងសំណួរ និងការសម្ភាសជាមួយសហគមន៍ក្នុងភូមិទាំងអស់ បញ្ជាក់យ៉ាងច្បាស់ថា អ្នកភូមិទទួលបានព័ត៌មានមិនគ្រប់គ្រាន់ពាក់ព័ន្ធនឹងក្រុមចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ អំពីដំណើរការនៃការស្រង់ទិន្នន័យនិងអំពីផែនការផ្ដល់សំណង និងការតាំងទីលំនៅថ្មី ដែលកំពុងស្នើសុំនោះឡើយ។ ក្នុងករណីខ្លះ អ្នកភូមិមិនទទួលបានព័ត៌មានអ្វីទាំងអស់។

ទោះបីជាអ្នកភូមិខ្លះទៀតបាននិយាយថា គេបានប្រាប់ពួកគាត់ថា ក្រុមចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ មានតំណាងក្រុមហ៊ុន អាជ្ញាធរមូលដ្ឋាន និងមេភូមិ និងនគរបាល ដោយមានអ្នកភូមិ ៧០% បាននិយាយថា ក្រុមចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនេះ មិនបានពន្យល់ថា អ្នកទាំងនោះជាអ្នកណា និងថា ហេតុអ្វីបានជាអ្នកទាំងនោះទៅទីនោះឡើយ។ ក្នុងករណីខ្លះ ក្រុមនេះបានមកដល់ដោយមិនបានប្រាប់មុន និងចុះស្រង់ទិន្នន័យដោយគ្មានការជូនដំណឹងជាមុន។[14]

---

13 កំណត់ចំណាំក្រៅផ្លូវការពីកិច្ចសម្ភាសន៍ជាមួយអ្នកភូមិដែលទទួលរងផលប៉ះពាល់នៅភូមិក្ដុក ដោយអង្គការឃ្លាំមើលទន្លេមេគង្គ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។

14 សេចក្ដីរាយការណ៍ក្រៅផ្លូវការពីបណ្ដាញការពារទន្លេ៣ (ប.ក.ស៣) ភូមិខ្ញុំ (MVi) ខែមករា ឆ្នាំ២០១៥។

## ការពន្យល់មិនគ្រប់គ្រាន់អំពីដំណើរការនៃការស្រង់ទិន្នន័យ និងឯកសារ

អ្នកភូមិច្រើនជាងពាក់កណ្ដាល (៥១%) ដែលយើងបានសួរ និយាយថា ក្រុមចុះស្រង់ទិន្នន័យនេះមិនបានពន្យល់ពួកគាត់ត្រឹមត្រូវអំពីដំណើរការនៃការស្រង់ទិន្នន័យនេះទេ។ នៅក្នុងភូមិខ្លះ តួលេខនៃការមិនបានពន្យល់ពួកគាត់ត្រឹមត្រូវអំពីដំណើរការនៃការស្រង់ទិន្នន័យនេះខ្ពស់ជាងក្នុងភូមិផ្សេងទៀត។ *៦៨% នៅក្នុងភូមិក្បាលរមាស និង៦២%នៅក្នុងភូមិស្រែគរ បានរាយការណ៍ថា ក្រុមចុះស្រង់ទិន្នន័យ មិនបានពន្យល់ពួកគាត់អំពីដំណើរការនៃការស្រង់ទិន្នន័យ ឬអំពីឯកសារស្រង់ទិន្នន័យនេះទេ*។ នៅភូមិក្បាលរមាស អ្នកភូមិម្នាក់បាននិយាយថា៖ "នៅពេលដែលក្រុមស្រង់ទិន្នន័យមកដល់ គេមិនបានពន្យល់ ឬបង្ហាញយើងនូវអ្វីទាំងអស់។ គេគ្រាន់តែសួរម្ចាស់ផ្ទះ ឬគ្រួសារថា តើគ្រួសារនេះមានផ្ទៃផ្ទះទំហំប៉ុនណា មានដើមស្វាយប៉ុន្មាន ឬដើមដូងប៉ុន្មាន ហើយកត់ចម្លើយ"។[15]

## ខ្វះការពិគ្រោះយោបល់ប្រកបដោយផ្លែផ្កា

ក្រុមស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ក៏មិនបានអនុញ្ញាត ឬមិនបានបញ្ចូលសមាជិកសហគមន៍ឡើយ។ *ជាងបីភាគបួន (៧៦%) នៃប្រជាសហគមន៍ដែលយើងបានសួររាយការណ៍ ថា គេមិនបានផ្ដល់ឱកាសឱ្យសួរសំណួរ ឬនិយាយអំពីដំណើរការនៃការស្រង់ទិន្នន័យនេះឡើយ។ នេះមានន័យថា ប្រជាពលរដ្ឋតិចជាងមួយភាគបួនត្រូវបានផ្ដល់ឱកាសឲ្យចូលរួមយ៉ាងសកម្មជាមួយដំណើរការនៃការស្រង់ទិន្នន័យ ឬសួរបញ្ជាក់អំពីឯកសារដែលទីបំផុតនឹងសម្រេចថា តើផ្ទះនិងដីរបស់ពួកគាត់មានតម្លៃប៉ុន្មាន និងថា តើពួកគាត់នឹងត្រូវទទួលបានសំណងប៉ុន្មាន។ នៅភូមិស្រែគរ មានអ្នកភូមិតែ១៧%ប៉ុណ្ណោះ ត្រូវគេផ្ដល់ឱកាសបែបនេះ។*

## កង្វះការយល់ដឹងអំពីដំណើរការនៃការស្រង់ទិន្នន័យ និងឯកសារស្រង់ទិន្នន័យ

ដោយសារ ប្រជាពលរដ្ឋភាគច្រើនមិនទទួលបាននូវការពន្យល់អំពីដំណើរការនៃការស្រង់ទិន្នន័យនេះ និងមិនទទួលបានឱកាសក្នុងការសួរសំណួរទេ ដូច្នេះវាប្រហែលជាមិនគួរឱ្យភ្ញាក់ផ្អើលទេដែលថា *អ្នកភូមិ៧៥%បានរាយការណ៍ថា ពួកគាត់មិនយល់អំពីឯកសារស្រង់ទិន្នន័យនេះ ឬអំពីសិទ្ធិ*របស់ពួកគាត់តែដែលត្រូវគេផ្ដល់សំណងជូន។ នេះមានន័យថា មានប្រជាពលរដ្ឋតែមួយភាគបួនប៉ុណ្ណោះ បានយល់ឯកសារដែលគេបានផ្ដល់ឱ្យ ឬបានយល់អំពីដំណើរការដែលនឹងសម្រេចអំពីតម្លៃទ្រព្យសម្បត្តិទាំងអស់របស់ពួកគាត់ និងអំពីសំណងដែលត្រូវផ្ដល់ជូន។ ឯកសារស្រង់ទិន្នន័យមានតែជាភាសាខ្មែរប៉ុណ្ណោះ ពុំមានជាភាសាជនជាតិដើមភាគតិច ដែលជាម្ចាស់មូលដ្ឋាននោះឡើយ។ មិនមានការបង្ហាញ ថា ក្រុមស្រង់ស្ថិតិទ្រព្យសម្បត្តិ បាន បញ្ចូលអ្នកដែលមានសមត្ថភាពទំនាក់ទំនងជាមួយនឹងជនជាតិដើមភាគតិចចូលក្នុងក្រុមរបស់ខ្លួនឡើយ។ ការនេះបានបិទឱកាសចូលរួមរបស់អ្នកភូមិខ្លះជាពិសេសស្ត្រីដែលមានកំរិតយល់ដឹងភាសាខ្មែរនៅទាប។ នៅភូមិស្រែគរ មានប្រជាជនតែ១៤% ប៉ុណ្ណោះ ដែលបានរាយការណ៍ថា ពួកគាត់យល់យ៉ាងច្បាស់អំពីដំណើរការនៃការស្រង់ទិន្នន័យ និងអំពីឯកសារស្រង់ទិន្នន័យនោះ។

15 www.mekongwatch.org/PDF/LS2_FieldNoteRegardingAssetSurvey.pdf

បុរសវ័យក្មេងម្នាក់នៅភូមិនេះនិយាយថា "ខ្ញុំមិនយល់អំពីឯកសារនោះទេ ហើយខ្ញុំមិនប្រាកដថា គេកំពុងធ្វើអ្វីនោះឡើយ"។[16] បុរសម្នាក់ទៀតនៅភូមិក្បាលរមាសនិយាយថា "គ្រួសារខ្លះដែលផ្ទះ និងដីរបស់គាត់ត្រូវបានវាស់វែងហើយនោះ បានយល់អំពីអត្ថន័យនៃការវាស់វែងនេះ ប៉ុន្តែគ្រួសារផ្សេងទៀតពិតជាមិនយល់ទេ"។[17]

% នៃអ្នកឆ្លើយតបក្នុងភូមិនីមួយៗដែលប្រាប់ថាពួកគាត់បានយល់ពីឯកសារសម្រង់ស្ថិតិ និងផែនការសំណង




## ការចូលរួមច្រើនដោយគ្មានការយល់ដឹង និងយល់ព្រមច្បាស់លាស់

ជាក់ស្តែង ទោះបីជាប្រជាសហគមន៍៧៥%ដែលត្រូវបានសម្ភាសន៍បាននិយាយថា ពួកគាត់មិនយល់អំពីដំណើរការនៃការស្រង់ទិន្នន័យ ឬឯកសារស្រង់ទិន្នន័យនេះក៏ដោយ ***ក៏អ្នកភូមិ៨៦%នៅក្នុងសហគមន៍ទាំងបួន បានរាយការណ៍ថា ពួកគាត់បានចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យនេះ និងបានផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យ***។ នេះមានន័យថា គ្រួសារភាគច្រើនដែលត្រូវបានសួរសំណួរ (នៅក្នុងការស្រាវជ្រាវស្វែងរកការពិត) ហើយដែលបានចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនោះ បានចូលរួមដោយពុំបានយល់ច្បាស់ ហើយបានផ្តិតមេដៃលើឯកសារច្បាប់យ៉ាងសំខាន់ដោយគ្មានការយល់ព្រមដែលបានដឹងច្បាស់ត្រឹមត្រូវឡើយ។

ហើយក៏មានភាពខុសគ្នាគួរកត់សម្គាល់ពាក់ព័ន្ធចំនួនប្រជាពលរដ្ឋដែលបានរាយការណ៍ថាពួកគាត់បានយល់ព្រមក្នុងការចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យនៅក្នុងសហគមន៍។ នៅភូមិស្រែគរ ៧៤% នៃប្រជាពលរដ្ឋដែលយើងបានសួរបានបដិសេធមិនចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យនេះទេ ក្នុងអំឡុងពេលដែលការស្រង់ទិន្នន័យនោះកំពុងត្រូវបានគេធ្វើឡើង ឬមិនព្រមផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យ។

16 បញ្ជីសំណួរទី១២៥

17 ឯកសារស្តីពី "កិច្ចសម្ភាសន៍នៅភូមិដែលទទួលរងផលប៉ះពាល់ នៅខែកុម្ភៈ ឆ្នាំ២០១៥ ពាក់ព័ន្ធនឹងការស្រង់ទិន្នន័យវាស់វែងទ្រព្យសម្បត្តិដែលប្រព្រឹត្តិទៅស្តីពីទំនប់វារីអគ្គិសនីសេសានក្រោម២, ខែមិថុនា ឆ្នាំឆ្នាំ២០១៥។

ភាគច្រើននៃប្រជាសហគមន៍ភូមិច្រប (៦៣%) និងភូមិក្បាលរមាស (៥៦%) ដែលយើងបានសួរ ក៏បានបដិសេធមិនសហការជាមួយក្រុមចុះស្រង់ទិន្នន័យ ឬមិនចូលរួមក្នុង ដំណើរការនេះដែរ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋ១០០%នៅភូមិស្រែស្រណុកដែលយើងបានសួរ និយាយថា ពួកគាត់បានយល់ព្រមចូលរួមក្នុងការស្រង់ទិន្នន័យ និងបានផ្តិតមេដៃ។ ប៉ុន្តែ រឿងនេះ បង្កើតឲ្យមាននូវសំណួរចំពោះភាពអាចយកជាការបាននៃការឯកភាពរបស់ពួកគេ ព្រោះថា ៥៩% នៃប្រជាពលរដ្ឋនៅភូមិស្រែស្រណុកដែលយើងបានសួរ និយាយថា ពួកគាត់មិនយល់អំពីដំណើរការនៃការស្រង់ទិន្នន័យ ឬឯកសារស្រង់ទិន្នន័យនេះទេ ទោះបីជាពួកគាត់បានចូលរួមនៅក្នុងដំណើរការនោះក៏ដោយ។

**ប្រជាពលរដ្ឋ ៣៥% ដែលមកពីក្នុងភូមិទាំងបួនដែលយើងបានសួរហើយដែលបានយល់ព្រមចូលរួមក្នុងការស្រង់ទិន្នន័យ និងបានផ្តិតមេដៃ និយាយថា ការពិតពួកគាត់មិនយល់អំពីដំណើរការ ឬឯកសារស្រង់ទិន្នន័យនៅពីមុខពួកគាត់នោះទេ។** ស្ត្រីម្នាក់នៅភូមិច្របបាននិយាយថា "*ខ្ញុំបានយល់ព្រម ប៉ុន្តែខ្ញុំមិនយល់ឯកសារនោះទេ រីឯក្រុមហ៊ុនមិនបានពន្យល់ខ្ញុំអំពីឯកសារនេះឱ្យបានត្រឹមត្រូវឡើយ។ ខ្ញុំមិនជឿអ្វីដែលគេនិយាយនោះទេ*"។[18] អ្នកភូមិម្នាក់ទៀតនិយាយថា៖ "*ខ្ញុំពិតជាមិនយល់អ្វីដែលបានកើតឡើងនោះទេ ហើយខ្ញុំមិនពូកែនិយាយទេ។ ខ្ញុំបានឃើញអ្នកភូមិផ្សេងៗ ព្រមចូលរួមធ្វើសម្រង់ទិន្នន័យនោះ ដូច្នេះខ្ញុំក៏ធ្វើដែរ។ ខ្ញុំមិនសប្បាយចិត្តចំពោះសំណងនោះទេ ព្រោះវាមិនឆ្លើយតបចំពោះផ្ទះបុព្វបុរសរបស់យើង ហើយគេមិនសងយើងជាសមូហភាពនោះទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានជម្រើសអ្វីផ្សេងទេ*"។[19]




18 បញ្ជីសំណួរទី៥៣។

19 បញ្ជីសំណួរទី២៣។

## ការខកខានក្នុងការផ្តល់ឯកសារ

ក្រុមការងារស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ខកខានមិនបានផ្តល់នូវទម្រង់ឯកសារស្រង់ទិន្នន័យដែលបានបំពេញរួច ឬឯកសារពាក់ព័ន្ធ ជូនដល់គ្រួសារជាច្រើនដែលបានចូលរួមក្នុងការស្រង់ទិន្នន័យនេះទេ។ **គ្រួសារដែលបានសហការជាមួយក្រុមការងារស្រង់ទិន្នន័យ ៤៤% បាននិយាយថា ពួកគាត់មិនទទួលបានឯកសារអ្វីទាំងអស់ក្រោយពីបានបញ្ចប់ដំណើរការនៃការស្រង់ទិន្នន័យនេះ។** នេះមានន័យថា ពួកគាត់ពិតជាគ្មានកំណត់ហេតុអំពីអ្វីដែលបានវាស់វែង ឬអំពីតម្លៃប៉ុន្មានសម្រាប់ទ្រព្យសម្បត្តិ និងដីធ្លីរបស់ពួកគាត់ទេ។ ពលរដ្ឋម្នាក់មកពីភូមិក្បាលរមាស និយាយថា៖ "*គេយកឯកសារទាំងអស់ទៅវិញ។ នៅពេលដែលគេឲ្យម្ចាស់ផ្ទះផ្តិតមេដៃ ម្ចាស់ផ្ទះអាចមើលឃើញផ្នែកខ្លះនៃឯកសារនោះ។ ពួកគាត់មិនបានឃើញចំណងជើងទេ*"។[20]

## ការខកខានក្នុងការបញ្ចូលសហគមន៍ទាំងអស់ដែលរងផលប៉ះពាល់ដោយសារគម្រោង

នៅភូមិភ្លុកពុំមានការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិទេ ទោះបីជាជាក់ស្តែងប្រជាសហគមន៍មួយចំនួនបានបាត់បង់រួចហើយក្តី ឬនឹងប្រឈមការបាត់បង់នូវដីធ្លី និងទ្រព្យសម្បត្តិដែលបណ្តាលមកពីគម្រោងនេះក្តី។ នៅភូមិភ្លុក អ្នកភូមិដែលទទួលរងផលប៉ះពាល់ មិនទទួលបាននូវសំណងដែលកំណត់ដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ត្រឹមត្រូវ និងឯកភាពគ្នា ដូចមានចែងនៅក្នុងគោលនយោបាយស្តីពីការតាំងទីលំនៅថ្មីនោះឡើយ។ យោងតាមអ្នកភូមិម្នាក់បាននិយាយរៀបរាប់ថា តំណាងក្រុមហ៊ុនបានមកដល់ភូមិនេះ កាលពីខែមេសាឆ្នាំ២០១៤ និងឲ្យប្រាក់៥០០ដុល្លារអាមេរិកទៅបណ្តាគ្រួសារដែលរងផលប៉ះពាល់ ជាការដោះដូរដីរបស់ពួកគាត់ដែលមានទំហំ៧ហិចតា។ តំណាងក្រុមហ៊ុននេះ បាននិយាយថា អ្នកភូមិអាចទទួលយកប្រាក់ ឬមិនយក ប៉ុន្តែប្រសិនបើ ពួកគាត់មិនយកទេ ប្រាក់នេះ នឹងឲ្យទៅអាជ្ញាធរ។ គេមិនបានឲ្យឯកសារ ឬព័ត៌មានសម្រាប់ទាក់ទងទេក្នុងការប្រតិបត្តិការនេះ។[21]

## ការភ័យខ្លាចទឹកលិច និងគ្មានជម្រើស

ក្នុងកម្រងសំណួរ អ្នកភូមិជាច្រើន ត្រូវបានអញ្ជើញឱ្យនិយាយពីហេតុផលតាមតែគាត់អាចនិយាយបានទាក់ទងនឹងការសម្រេចចិត្តរបស់ពួកគាត់ ក្នុងការចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ។ លទ្ធផលបង្ហាញថា ការសម្រេចចិត្តរបស់ពួកគាត់គឺដោយសារឥទ្ធិពលនៃការភ័យខ្លាចយ៉ាងខ្លាំង និងមានជំនឿទាំងស្រុងថា ពួកគាត់គ្មានជម្រើសពិតប្រាកដទេ។ ប្រជាពលរដ្ឋ ៦៧%ដែលបានលើកហេតុផល និយាយថា ពួកគាត់មានអារម្មណ៍ថា ពួកគាត់គ្មានជម្រើសទេ ហើយ ៤៤% ទៀតនិយាយដែរថា ពួកគាត់បានយល់ព្រម ព្រោះខ្លាចមានផលវិបាក។

20 ឯកសារស្តីពី "កិច្ចសម្ភាសន៍នៅភូមិដែលទទួលរងផលប៉ះពាល់ នៅខែកុម្ភៈ ឆ្នាំ២០១៥ ពាក់ព័ន្ធនឹងការស្រង់ទិន្នន័យវាស់វែងទ្រព្យសម្បត្តិដែលប្រព្រឹត្តិទៅស្តីពីទំនប់វារីអគ្គិសនីសេសានក្រោម២, ខែមិថុនា ឆ្នាំឆ្នាំ២០១៥

21 កំណត់ចំណាំក្រៅផ្លូវការពីកិច្ចសម្ភាសន៍ជាមួយអ្នកភូមិដែលទទួលរងផលប៉ះពាល់នៅភូមិភ្លុក ដោយអង្គការឃ្លាំមើលទន្លេមេគង្គ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។

ផលវិបាកដែលពួកគាត់ខ្លាចបំផុតពីការមិនចូលរួមគឺ ផ្ទះសម្បែងដីធ្លីរបស់ពួកគាត់ នឹងត្រូវទឹកលិចដោយសារគម្រោង ហើយដោយគ្មានទទួលបានសំណងអ្វីទាំងអស់។ **មានប្រជាពលរដ្ឋតែ៤%ប៉ុណ្ណោះនិយាយថា ពួកគាត់សុខចិត្តចូលរួម ព្រោះពួកគាត់យល់ស្របជាមួយនឹងក្រុមហ៊ុន។**

អ្នកភូមិមានអារម្មណ៍ថា ពួកគាត់គ្មានជម្រើស ដោយទន្ទឹមនឹងគ្នានេះដែរ ក៏មានការភ័យខ្លាចពីការទឹកលិច។ អ្នកភូមិបានរៀបរាប់ពីការភ័យខ្លាចថា មិនយូរទេ ផ្ទះរបស់ពួកគាត់នឹងត្រូវទឹកលិច និងប្រសិនបើ ពួកគាត់មិនសហការជាមួយដំណើរការនៃការស្រង់ទិន្នន័យ នៅថ្ងៃនោះទេ នោះក្រោយមកពួកគាត់នឹងគ្មានសល់អ្វីឡើយ។ ស្ត្រីម្នាក់មកពីភូមិក្បាលរមាសនិយាយថា "*ខ្ញុំភ័យខ្លាចទឹកលិច ហើយខ្ញុំគ្មានលុយទិញផ្ទះថ្មីទេ។តើខ្ញុំមានជម្រើសអ្វី?*"[22] អ្នកភូមិម្នាក់ទៀតនិយាយថា "*ខ្ញុំបានយល់ព្រមនឹងការស្រង់ទិន្នន័យនេះ ព្រោះខ្ញុំគ្មានជម្រើសទេ។ ខ្ញុំខ្លាចព្រោះថា ប្រសិនបើ ដីនោះត្រូវទឹកលិច ខ្ញុំនឹងមិនមានកន្លែងរស់នៅទេនិងគ្មាននរណានឹងជួយខ្ញុំទេនៅពេលនោះ*"។[23] នៅភូមិស្រែគរស្ត្រីម្នាក់អាយុ៦០ឆ្នាំនិយាយថា៖ "*ខ្ញុំភ័យខ្លាចទឹកលិច ហើយខ្ញុំគ្មានប្រាក់សម្រាប់សាងសង់ផ្ទះថ្មីទេ។ ខ្ញុំភ័យខ្លាចបាត់បង់ដីទាំងអស់របស់ខ្ញុំ ហើយប្រសិនបើភូមិនេះត្រូវទឹកលិច តើឲ្យខ្ញុំទៅណា? ខ្ញុំគ្មានជម្រើសទេ*"។[24] ស្ត្រីវ័យក្មេងម្នាក់ទៀតនិយាយថា៖ "*គេនិយាយថា ប្រសិនបើខ្ញុំមិនចូលរួមក្នុងការស្រង់ទិន្នន័យនេះទេ នោះក្រុមហ៊ុននឹងមិនទទួលខុសត្រូវទេ នៅថ្ងៃក្រោយ។ ខ្ញុំពិតជាគ្មានជម្រើសទេ*"។[25]

ការភ័យខ្លាចនិងភាពមិនច្បាស់លាស់អំពីអនាគតនៃសហគមន៍ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នៃការសិក្សាស្រាវជ្រាវនេះ។ របាយការណ៍នេះ បានឆ្លុះបញ្ចាំងអំពីស្ថានភាពធ្ងន់ធ្ងររបស់អ្នកភូមិ និងផលប៉ះពាល់យ៉ាងខ្លាំងលើជីវភាពរស់នៅរបស់ពួកគាត់ ដោយសារគម្រោងនេះ។ លើសពីនេះទៅទៀត ចម្លើយទាំងនោះបង្ហាញថា ប្រជាពលរដ្ឋជាច្រើនមានអារម្មណ៍ថា ពួកគាត់មានឱកាសតែមួយគត់គឺសហការ និងចូលរួមបំពេញសម្រង់ទិន្នន័យ នៅថ្ងៃដែលគេបានបង្ហាញដល់ពួកគាត់។ ពួកគាត់មិនជឿថា នឹងមានឱកាសណាទៀតដើម្បីពិចារណាលើលក្ខខណ្ឌនៃកញ្ចប់សំណង និងការតាំងទីលំនៅថ្មី ស្នើសុំព័ត៌មានបន្ថែម ឬរៀបចំការពិភាក្សាជាមួយគណៈកម្មការតាំងលំនៅថ្មី ឬក្រុមហ៊ុននោះឡើយ។ លើសពីនេះទៅទៀត នេះមិនមែនជាការសន្និដ្ឋាននោះទេ ប៉ុន្តែហាក់ដូចជាបានបង្ហាញនូវលទ្ធផលផ្ទាល់ពីអ្វីដែលអ្នកភូមិទាំងនោះបានដឹង ក្នុងកំឡុងពេលនៃដំណើរការនៃការស្រង់ទិន្នន័យនេះ។ បុរសម្នាក់មកពីភូមិក្បាលរមាសនិយាយថា "*ខ្ញុំយល់ព្រម ព្រោះកាលនោះខ្ញុំខ្លាចផ្ទះរបស់ខ្ញុំ និងទ្រព្យសម្បត្តិរបស់ខ្ញុំត្រូវទឹកលិចដោយសារទំនប់វារីអគ្គិសនីនេះ ហើយប្រសិនបើខ្ញុំមិនយល់ព្រមចូលរួមក្នុងការស្រង់ទិន្នន័យនេះទេ ខ្ញុំនឹងមិនទទួលបានសំណងអ្វីទាំងអស់។ ក្រុមហ៊ុនបានប្រាប់យើងថា ប្រសិនបើខ្ញុំមិនព្រមចាកចេញពីផ្ទះរបស់ខ្ញុំទេ ពេលនោះ គេនឹងមិនទទួលខុសត្រូវទេនៅពេលក្រោយ*"។[26] ស្ត្រីម្នាក់ទៀតមកពីភូមិស្រែស្រណុកនិយាយថា៖ "*ប្រសិនបើខ្ញុំមិនយល់ព្រមទេ គេនឹងមិនឱ្យសំណងឡើយ ហើយវានឹងបណ្តាលឱ្យមានបញ្ហាដល់ខ្ញុំនៅពេលក្រោយ។*

---

22 បញ្ជីសំណួរទី២១៨។

23 បញ្ជីសំណួរទី២០។

24 បញ្ជីសំណួរទី១៣០។

25 បញ្ជីសំណួរទី១៦៤។

26 បញ្ជីសំណួរទី២៩។

*ខ្ញុំដឹងថា ប្រសិនបើខ្ញុំមិនសហការទេ នោះក្រុមហ៊ុននឹងមិនជួយយើងទេ ដូច្នេះខ្ញុំគ្មានជម្រើសទេ"*។[27]

តាមរយៈក្រុមចុះស្រង់ទិន្នន័យបានបង្ហាញថា ការស្រង់ទិន្នន័យទ្រព្យសម្បត្តិនេះ ជាឱកាសចុងក្រោយដើម្បីទទួលបានសំណង ដោយមនុស្សជាច្រើនក្នុងសហគមន៍រួមទាំងមនុស្សចាស់ និងក្រុមងាយរងគ្រោះផង មានអារម្មណ៍រងសម្ពាធក្នុងការចូលរួមការស្រង់ទិន្នន័យ ទោះបីពួកគាត់មិនយល់ ឬមិនឯកភាពនឹងដំណើរការនោះក៏ដោយ ពីព្រោះពួកគាត់មានការភ័យខ្លាចចំពោះផលវិបាកនៃការមិនចូលរួមរបស់ពួកគាត់។

## អារម្មណ៍ខ្លាច ភិតភ័យ និងគាបសង្កត់អំឡុងពេលចុះស្រង់ទិន្នន័យទ្រព្យសម្បត្តិ

**ជិតពាក់កណ្ដាល (៤៧%) នៃអ្នកភូមិដែលយើងបានសួរ ហើយដែលបានចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យ និងផ្ដិតមេដៃ បាននិយាយថា ពួកគាត់មានអារម្មណ៍ ភ័យខ្លាច ត្រូវគេគាបសង្កត់ ឬបំភិតបំភ័យ ក្នុងអំឡុងពេលស្រង់ទិន្នន័យនេះ។** តាមចម្លើយដែលយើងទទួលបាន បង្ហាញច្បាស់ណាស់ថា ប្រជាពលរដ្ឋខ្លះ មានអារម្មណ៍ថា ពួកគាត់ត្រូវប៉ូលីស អាជ្ញាធរ និងក្រុមហ៊ុន គំរាមកំហែងនិងបំភិតបំភ័យ។ ស្ត្រីវ័យក្មេងម្នាក់មកពីភូមិក្បាលរមាសនិយាយថា៖ *"អាជ្ញាធរភូមិ បានប្រាប់អ្នកភូមិឱ្យយល់ព្រមឱ្យគេវាស់វែងផ្ទះរបស់ពួកគាត់។ អាជ្ញាធរនិយាយថា អ្នកភូមិមិនត្រូវតវ៉ាប្រឆាំងនឹងរដ្ឋាភិបាលទេហើយដោយសារយើងជាពលរដ្ឋសាមញ្ញយើងត្រូវតែគោរពថ្នាក់លើ"*។[28] អ្នកភូមិម្នាក់ទៀតនិយាយថា៖ *"កាលនោះ ខ្ញុំខ្លាច និងមានអារម្មណ៍ថាត្រូវគេគំរាមកំហែង។ ក្រុមការងារស្រង់ទិន្នន័យបានចុះមកធ្វើការដោយគ្មានការពិគ្រោះយោបល់ជាមួយខ្ញុំទេ។ខ្ញុំគ្មានជម្រើសឡើយ"*។[29] ហើយអ្នកភូមិម្នាក់ផ្សេងទៀតនិយាយថា៖ *"ក្រុមហ៊ុនបានគំរាមខ្ញុំ ហើយខ្ញុំខ្លាចគេចាប់ខ្ញុំដាក់ខ្នោះ"*។[30]

បញ្ហាដែលសហគមន៍បានជួបប្រទះ មានភាពផ្សេងៗគ្នាក្នុងភូមិទាំងបួន។ នៅតាមភូមិដែលប្រជាជនភាគច្រើនបានបដិសេធមិនចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យ មានសេចក្ដីរាយការណ៍តិចតួចអំពីការភ័យខ្លាច ការបំភិតបំភ័យ និងការគាបសង្កត់។ ឧទាហរណ៍ នៅភូមិស្រែគរដែលមានប្រជាពលរដ្ឋ៧៤% បានបដិសេធ មានសេចក្ដីរាយការណ៍១៣% អំពីអារម្មណ៍ភ័យខ្លាច ភិតភ័យ ឬត្រូវគេគាបសង្កត់។ ដោយហេតុថាទោះតួលេខយ៉ាងណាក៏ជាក្ដីបារម្ភដែរនោះ តួលេខសម្រាប់ភូមិស្រែស្រណុក ធ្វើឲ្យមានមន្ទិលសង្ស័យលើសុពលភាពនៃដំណើរការនៃការស្រង់ទិន្នន័យទាំងមូល។ **នៅភូមិស្រែស្រណុក ដែលមានប្រជាពលរដ្ឋ១០០%ដែលយើងសួរ បាននិយាយថា ពួកគាត់បានចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យ មាន៦១% បានរាយការណ៍ថា មានអារម្មណ៍ខ្លាច ភិតភ័យ និងត្រូវគេគាបសង្កត់ នៅក្នុងអំឡុងពេលនៃដំណើរការស្រង់ទិន្នន័យ។**

---

27 បញ្ជីសំណួរទី៤០។

28 ឯកសារស្ដីពី "កិច្ចសម្ភាសន៍នៅភូមិដែលទទួលរងផលប៉ះពាល់ នៅខែកុម្ភៈ ឆ្នាំ២០១៥ ពាក់ព័ន្ធនឹងការស្រង់ទិន្នន័យវាស់វែងទ្រព្យសម្បត្តិដែលប្រព្រឹត្តិទៅស្ដីពីទំនប់វារីអគ្គិសនីសេសានក្រោម២, ខែមិថុនា ឆ្នាំឆ្នាំ២០១៥

29 បញ្ជីសំណួរទី២៦៧។

30 បញ្ជីសំណួរទី៨២។

ស្ត្រីវ័យ៨០ឆ្នាំម្នាក់មកពីភូមិស្រែស្រណុកនិយាយថា៖ *"ខ្ញុំខ្លាចរដ្ឋាភិបាល។ គេនឹងមិនផ្តល់សំណងឲ្យខ្ញុំទេ នៅពេលមានទឹកលិច ដូច្នេះខ្ញុំបានយល់ព្រមជាមុន។ អាជ្ញាធរបានប្រាប់យើង ឱ្យធ្វើដូច្នេះ អ៊ីចឹងហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានជម្រើសទេ"*។[31] ស្ត្រីម្នាក់ទៀតនិយាយថា *"ខ្ញុំបានយល់ព្រម ព្រោះអាជ្ញាធរ និងក្រុមហ៊ុនគំរាមខ្ញុំ។ ក្រុមហ៊ុននេះបានប្រាប់ខ្ញុំថា ប្រសិនបើ ពេលនេះខ្ញុំមិនព្រមទេ នោះក្រោយមក បើមានអ្វីកើតឡើងគេនឹងមិនទទួលខុសត្រូវទេ និងថា ប្រសិនបើខ្ញុំមិនព្រមទេ ផ្ទះរបស់ខ្ញុំនឹងត្រូវទឹកលិច"*។[32] ស្ត្រីម្នាក់ទៀតនិយាយថា "ខ្ញុំបានយល់ព្រមព្រោះគេបានប្រាប់ខ្ញុំឱ្យធ្វើសម្រង់ទិន្នន័យនេះ និងថា ឲ្យខ្ញុំធ្វើតាមតែគេទៅ។ ខ្ញុំមិនយល់ព្រមជាមួយនឹងតម្លៃសម្រាប់ផលដំណាំ និងចម្ការរបស់ខ្ញុំទេ ព្រោះគេឲ្យតិចពេក។ ខ្ញុំមានអារម្មណ៍ថា គេគាបខ្ញុំឲ្យផ្ចិតមេដៃ ព្រោះគេនិយាយថា ប្រសិនបើ អ្នកភូមិយល់ព្រមចាកចេញពីភូមិ គេនឹងផ្តល់សំណងឲ្យយើង។[33]




## វត្តមានមន្ត្រីនគរបាល និងកង្វះចំណេះដឹងអំពីសិទ្ធិរបស់ពួកគាត់

ហេតុផលមួយក្នុងចំណោមហេតុផលនានា ដែលនាំឲ្យប្រជាពលរដ្ឋមានអារម្មណ៍ខ្លាច នៅពេលធ្វើសម្រង់ទិន្នន័យនោះ អាចមកពីមានមន្ត្រីនគរបាលច្រើនពេលក្រុមការងារចុះធ្វើសម្រង់ទិន្នន័យនៅក្នុងភូមិ។ ប្រជាពលរដ្ឋភាគច្រើនលើសលប់ដែលបានចូលរួមឆ្លើយសំណួរបញ្ជាក់ថា នៅពេលដែលក្រុមការងារស្រង់ទិន្នន័យចុះមកភូមិ មានមន្ត្រីនគរបាលអមមកជាមួយ។ មានអ្នកផ្តល់ចម្លើយ៩១% បានបញ្ជាក់ថា យ៉ាងហោចណាស់មានមន្ត្រីនគរបាលម្នាក់អមដំណើរក្រុមចុះមកស្រង់ទិន្នន័យ។[34]

---

31 បញ្ជីសំណួរទី៦២។

32 បញ្ជីសំណួរទី៦៣។

33 បញ្ជីសំណួរទី៤៨។

34 សរុបចំនួនប្រជាពលរដ្ឋដែលបង្កើតបាជាក្រុមស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ចាប់ពី៥ទៅ២០នាក់។

ស្ត្រីម្នាក់នៅភូមិស្រែស្រណុក និយាយថាៈ *"ខ្ញុំខ្លាចខ្លាំងណាស់ ព្រោះគេមកដោយជិះរថយន្តធំៗ ហើយទំនើបៗ និងអមដោយនគរបាល ... ខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានជម្រើសទេ ក្រៅពីធ្វើតាមការណែនាំ ខ្ញុំខ្លាច"*។[35] នៅក្នុងបរិយាកាសប្រកបដោយការភ័យខ្លាចបែបនេះ វាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដែលប្រជាពលរដ្ឋខ្លះទទួលរងឥទ្ធិពលដោយឃើញមានមនុស្សផ្សេងសហការជាមួយក្រុមការងារចុះស្រង់ទិន្នន័យ។ ប្រជាពលរដ្ឋ៣៦%បានលើកឡើងថា រឿងបែបហ្នឹងក៏ជាហេតុនាំឲ្យពួកគាត់ចូលរួមដែរ។

លើសពីនេះ ប្រជាពលរដ្ឋដែលធ្លាប់បានឆ្លងកាត់ការភ័យខ្លាច ការបំភិតបំភ័យ ឬការគាបសង្កត់មានការព្រួយបារម្ភថា ពួកគាត់មិនបានដឹងថា ខ្លួនគាត់មានសិទ្ធិអ្វីខ្លះនោះទេ។ ស្ត្រីម្នាក់មកពីភូមិស្រែស្រណុកនិយាយថាៈ *"ខ្ញុំយល់ព្រមធ្វើសម្រង់ទិន្នន័យ ដោយសារខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានជម្រើស។ ខ្ញុំបារម្ភថា យើងនឹងមិនទទួលបានសំណងសមរម្យ និង ថាជីវភាពរបស់យើងខុសគ្នាឆ្ងាយនៅភូមិថ្មីរបស់យើង។ ខ្ញុំខ្លាចថា ក្រុមហ៊ុននឹងធ្វើឱ្យប៉ះពាល់ដល់ពួកយើង ព្រោះយើងមិនយល់អំពីច្បាប់ និងសិទ្ធិរបស់យើង"*។[36]

រឿងសំខាន់ដែលត្រូវកត់សម្គាល់គឺថា នៅពេលដែលអ្នកភូមិនិយាយថា ពួកគាត់គ្មានអារម្មណ៍ភ័យខ្លាច គ្មានការបំភិតបំភ័យ ឬការគាបសង្កត់ នោះហេតុផលងាយៗជាទូទៅគឺដោយសារ ពួកគាត់បានធ្វើអ្វីដែលក្រុមហ៊ុន និងអាជ្ញាធរបានប្រាប់ពួកគាត់ឱ្យធ្វើបែបនោះ។ ស្ត្រីម្នាក់អាយុ៨០ឆ្នាំ មកពីភូមិស្រែស្រណុក បានសង្ខេបអារម្មណ៍ដែលប្រជាពលរដ្ឋជាច្រើនគ្រាន់តែនិយាយថា "ខ្ញុំមិនភ័យខ្លាចទេព្រោះខ្ញុំសហការជាមួយគេ"។[37]

## ក្រុមហ៊ុនសន្យា ប៉ុន្តែខ្វះការទុកចិត្ត

ជាមួយនឹងការភ័យខ្លាច និងកង្វះការជ្រើសរើស អ្នកភូមិជាច្រើនបាននិយាយអំពីការសន្យាដែលក្រុមហ៊ុនបានសន្យាជាមួយពួកគាត់ ជាផ្នែកនៃផែនការផ្តល់សំណង និងការតាំងទីលំនៅថ្មី ដូចជា សន្យាផ្តល់ផ្ទះថ្មីកាន់តែល្អ ដីសម្រាប់ធ្វើកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងសំណងជាហិរញ្ញវត្ថុជាដើម។ មានប្រជាពលរដ្ឋ៥៦%និយាយថា ការសន្យានេះ ក៏ជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់ពួកគាត់ ក្នុងការសហការជាមួយនឹងដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនោះដែរ។ ការសន្យាសំខាន់បំផុតមានពីរ គឺ ក្រុមហ៊ុននឹងសាងសង់ផ្ទះថ្មីៗ នៅក្នុងសហគមន៍ និងផ្តល់ដីទំហំធំល្មមសម្រាប់ដាំបន្លែ ធ្វើស្រែ និងចិញ្ចឹមសត្វ។ ៧០% នៃអ្នកដែលយល់ព្រមបានបញ្ជាក់ថា ការសន្យានេះហើយដែលលើកទឹកចិត្តឱ្យពួកគាត់សហការ។ មានតែ១៥% ប៉ុណ្ណោះដែលនិយាយថា ការសន្យាឲ្យប្រាក់ជាហេតុនាំឲ្យពួកគាត់សហការ និង ១៥% ទៀតនិយាយថា ការសន្យាស្តារឡើងវិញនូវដីចម្ការ និងហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ដូចជាជង្រុក ក្រោលគោ ទ្រុងមាន់ជាដើមធ្វើឲ្យមានឥទ្ធិពលលើការសម្រេចចិត្តរបស់ពួកគាត់។

នៅភូមិស្រែគរ បុរសពីរនាក់និយាយថា ក្រុមហ៊ុនបានសន្យាផ្តល់ឱ្យពួកគាត់នូវទឹកប្រាក់ ៦០០០ដុល្លារជាប្រាក់សំណង និងដី៥ហិចតាសម្រាប់គ្រួសារនីមួយៗ។[38]

35 បញ្ជីសំណួរទី៣០។

36 បញ្ជីសំណួរទី៧៥។

37 បញ្ជីសំណួរទី៦២។

38 បញ្ជីសំណួរទី១១២ និង១១៧។

ស្ត្រីម្នាក់ទៀតមកពីភូមិស្រែគរដែរ និយាយថា *"ខ្ញុំបានយល់ព្រមរុះរើចេញ ព្រោះគេបានសន្យាថានឹងសង់ផ្ទះថ្មីមួយឲ្យ និងឱ្យខ្ញុំនូវអ្វីៗដែលខ្ញុំត្រូវការ"*។[39] នៅភូមិច្រប់ក៏មានចម្លើយស្រដៀងគ្នានេះដែរ ដោយមានបុរសម្នាក់និយាយថា៖ *"ក្រុមហ៊ុនបានសន្យាឲ្យយើងអ្វីៗគ្រប់យ៉ាង ដូចជា ផ្ទះថ្មីមួយខ្នង ដីលំនៅដ្ឋាន ដីដាំដំណាំ សំណង ក្រោលគោ និងជង្រុក ជាដើម"*។[40]

ទោះជាយ៉ាងនេះក្តី វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា ចម្លើយទាំងនេះនៅតែអមមកជាមួយនូវការភ័យខ្លាច និងកង្វល់ជាធម្មតាដែលស្តែងឡើងដោយប្រជាពលរដ្ឋផ្សេងៗទៀត នៅក្នុងសហគមន៍ និងជំនឿដែលគេជឿថា ពួកគាត់មានជម្រើសតិចតួច ព្រោះផ្ទះសម្បែង និងដីធ្លីរបស់ពួកគាត់នឹងត្រូវទឹកលិចដោយសារអាង និងថាពួកគាត់នឹងទទួលរងការលំបាកថែមទៀតនៅក្នុងរយៈពេលវែង។ ឧទាហរណ៍ ស្ត្រីម្នាក់អាយុ៣២ឆ្នាំមកពីភូមិស្រែគរ និយាយថា *"ខ្ញុំបានយល់ព្រមសហការណ៍ជាមួយសម្រង់មតិនេះ ព្រោះក្រុមហ៊ុនបានសន្យាឲ្យយើងនូវផ្ទះថ្មី និងដី ហើយគេបានប្រាប់យើងថា គេនឹងឱ្យពួកយើងនូវអង្ករ២០គីឡូក្រាមជារៀងរាល់ខែ។ ខ្ញុំដឹងមិនប្រាកដអំពីការស្រង់ទិន្នន័យនេះទេ ប៉ុន្តែខ្ញុំបានឃើញអ្នកភូមិគេធ្វើអ៊ីចឹង ហើយខ្ញុំខ្លាចបាត់បង់ និងទឹកលិចដីធ្លី និងផ្ទះសម្បែងរបស់ខ្ញុំ ដូច្នេះខ្ញុំគិតថា ខ្ញុំគ្មានជម្រើសទេ"*។ បុរសម្នាក់ទៀតមកពីភូមិច្រប់និយាយថា *"ខ្ញុំបានយល់ព្រម ក្នុងដំណើរការស្រង់ស្ថិតិទ្រព្យសម្បត្តិ ព្រោះក្រុមហ៊ុនបានសន្យាថា នឹងឱ្យខ្ញុំនូវផ្ទះកាន់តែធំ និងល្អជាងផ្ទះរបស់ខ្ញុំបច្ចុប្បន្ន និងបានសន្យាថានឹងផ្តល់សំណងសមរម្យឲ្យខ្ញុំ ប៉ុន្តែខ្ញុំក៏ខ្លាចដែរ ព្រោះថាប្រសិនបើខ្ញុំមិនយល់ព្រមទេ ពេលនោះក្រុមហ៊ុនច្បាស់ជាឈូសឆាយកម្ទេចផ្ទះខ្ញុំមិនខាន"*។[41]

អ្នកភូមិដែលបានផ្តល់ចម្លើយមានការមិនទុកចិត្ត និងការភ័យខ្លាចថា នៅថ្ងៃខាងមុខពួកគាត់នឹងត្រូវក្រុមហ៊ុនបោកប្រាស់។ បុរសម្នាក់អាយុ៦៣ឆ្នាំ និយាយថា៖ *"ខ្ញុំខ្លាចក្រុមហ៊ុនមិនរក្សាពាក្យសន្យា និងខ្លាចមានរឿងអ្វីកើតឡើង នៅពេលដែលយើងរុះរើផ្ទះសម្បែងចាកចេញពីភូមិរបស់យើង។ ប្រសិនបើយើងមិនទទួលបាននូវសំណងទេ ខ្ញុំនឹងមិនរុះរើចេញពីភូមិរបស់ខ្ញុំទេ។ ខ្ញុំសូមអំពាវនាវទៅមេឃុំ និងក្រុមការងារស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិឲ្យរកដំណោះស្រាយចំពោះកង្វល់ទាំងនេះជូនពួកយើង"*។[42] បុរសវ័យក្មេងម្នាក់ទៀតអាយុ១៩ឆ្នាំនិយាយថា "ខ្ញុំខ្លាចក្រុមហ៊ុននេះក្បត់ពាក្យសន្យា។ ខ្ញុំសុំក្រុមហ៊ុននិងអាជ្ញាធរមូលដ្ឋាន សូមផ្តល់សំណងឲ្យយើងឲ្យបានសមរម្យ"។[43] ម្នាក់ទៀតនិយាយថា៖ *"ខ្ញុំខ្លាចក្រុមហ៊ុន មិនផ្តល់សំណងសមរម្យឲ្យពួកយើង និងបោកយើង។ ប្រសិនបើ ក្រុមហ៊ុនមិនផ្តល់សំណងសមរម្យទេ ខ្ញុំនឹងមិនរុះរើចេញពីភូមិរបស់ខ្ញុំទេ"*។[44] ស្ត្រីម្នាក់ទៀតនិយាយថា *"ខ្ញុំសុំឲ្យក្រុមហ៊ុនរក្សាពាក្យសន្យារបស់ខ្លួន និងសូមកុំកុហកយើង"*។[45]

---

39 បញ្ជីសំណួរទី១៣៥។

40 បញ្ជីសំណួរទី១២៣។

41 បញ្ជីសំណួរទី៥៤។

42 បញ្ជីសំណួរទី៥០។

43 បញ្ជីសំណួរទី៥១។

44 បញ្ជីសំណួរទី៣២។

45 បញ្ជីសំណួរទី៣៤។

## ហេតុអ្វីបានជាប្រជាពលរដ្ឋជាច្រើនបដិសេធមិនចូលរួម

ទោះបីជាអ្នកភូមិមានការភ័យខ្លាច និងការច្របូកច្របល់ ពីភូមិមួយទៅភូមិមួយក៏ដោយ អ្នកភូមិ៥៥%ដែលយើងបានសួរ និយាយថា ពួកគាត់បានបដិសេធមិនសហការជាមួយដំណើរការនៃការស្រង់ទិន្នន័យទ្រព្យសម្បត្តិ និងមិនផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យនោះទេ។ ការពិត លើកលែងតែភូមិស្រែស្រណុកចេញ ប្រជាពលរដ្ឋភាគច្រើនដែលយើងសួរនៅក្នុងភូមិបីផ្សេងទៀត បានសម្រេចចិត្តមិនធ្វើដូច្នោះទេ។ មានហេតុផលជាច្រើនចំពោះការសម្រេចចិត្តបែបនេះ ហើយអ្នកភូមិត្រូវបានលើកទឹកចិត្តឲ្យផ្តល់ហេតុផលតាមតែពួកគាត់ចង់និយាយ។

**មានអ្នកភូមិ៨៥%និយាយថា ពួកគាត់បានបដិសេធ ព្រោះពួកគាត់មិនចង់ចាកចេញពីដីរបស់ពួកគាត់ទេ ហើយមានជិតពាក់កណ្តាល (៤៨%) និយាយថា នេះគឺដោយសារ នោះជាដីដូនតារបស់ពួកគាត់។ មាន៣០% ទៀតនិយាយផ្តោតសំខាន់ទៅលើការបាត់បង់ធនធានធម្មជាតិដ៏សម្បូរបែប និងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯងដែលមាននៅក្នុងតំបន់ជុំវិញ និងអំពីស្ថានភាពលំបាករកប្រាក់ចំណូល និងជីវភាពរស់នៅបណ្តាលមកពីការតាំងទីលំនៅថ្មី។**

ស្ត្រីម្នាក់មកពីភូមិស្រែគរ និយាយថា *"ខ្ញុំមិនចង់រុះរើទៅតាំងទីលំនៅថ្មីទេ។ ភូមិចាស់របស់យើងមានធនធានធម្មជាតិសម្បូរបែប និងស្រស់ស្អាត។ ដីបញ្ចុះសពបុព្វបុរសរបស់យើង មិនអាចផ្លាស់ប្តូរបានទេ រីឯទន្លេក៏មិនអាចទៅតាមយើងដែរ។ យើងមិនត្រូវការទំនប់វារីអគ្គិសនីនេះទេ"*។[46] ស្ត្រីវ័យចំណាស់ម្នាក់មកពីភូមិច្រប និយាយថា៖ *"គេនិយាយថា ផ្ទះរបស់យើងនឹងត្រូវទឹកលិច ប៉ុន្តែខ្ញុំនៅតែមិនព្រមព្រោះខ្ញុំមិនអាចចាកចេញពីផ្នូររក្សាឆ្អឹងបុព្វបុរសរបស់ខ្ញុំទេ"*។[47] ពលរដ្ឋម្នាក់ទៀតនិយាយថា៖ *"ខ្ញុំបដិសេធព្រោះខ្ញុំនឹងបាត់បង់ដើមឈើហូបផ្លែរបស់ខ្ញុំ បាត់បង់ទន្លេនិងចម្ការរបស់ខ្ញុំ ដែលខ្ញុំទទួលផលជារៀងរាល់ឆ្នាំ ដើម្បីចិញ្ចឹមគ្រួសាររបស់ខ្ញុំ។ ប្រសិនបើខ្ញុំចាកចេញ ខ្ញុំនឹងបាត់បង់សន្តិសុខស្បៀងអាហារនិងជីវភាពរស់នៅរបស់ខ្ញុំ"*។[48] សូម្បីតែបុរសម្នាក់មកពីភូមិស្រែស្រណុកដែលបានយល់ព្រមចូលរួមក្នុងការស្រង់ទិន្នន័យនេះក៏និយាយដែរថា៖ *"ខ្ញុំមិនចង់បានសំណង ឬការតាំងទីលំនៅថ្មីទេ។ ភូមិចាស់របស់ខ្ញុំមានភាពសុខសាន្ត ហើយខ្ញុំមិនត្រូវការរស់នៅកន្លែងណាផ្សេងទៀតទេ។ នៅភូមិនេះខ្ញុំមានអ្វីៗគ្រប់យ៉ាង។ ខ្ញុំមិនអាចចាកចេញពីដីរបស់ខ្ញុំ ឬទន្លេទេ ហើយយើងត្រូវតែថែរក្សាដីដូនតារបស់យើង"*។[49]

ហេតុផលមួយផ្សេងទៀតចំពោះការបដិសេធមិនចូលរួមគឺ ការផ្តល់កញ្ចប់សំណង ឬការតាំងទីលំនៅថ្មីនេះមិនល្អគ្រប់គ្រាន់សម្រាប់អ្នកភូមិរស់នៅ។ **មានប្រជាពលរដ្ឋ២៤% និយាយថា អ្វីដែលគេបម្រុងផ្តល់ឲ្យនោះ មិនឆ្លើយតប ទៅនឹងតម្លៃទ្រព្យសម្បត្តិដែលពួកគាត់នឹងបាត់បង់នោះឡើយ។**

---

46 បញ្ជីសំណួរទី១១៤។

47 បញ្ជីសំណួរទី៧។

48 បញ្ជីសំណួរទី៦។

49 បញ្ជីសំណួរទី១០០។

ស្ត្រីម្នាក់មកពីភូមិក្បាលរមាសនិយាយថា៖ "*ខ្ញុំបដិសេធ ព្រោះគេមិនដែលស្នើផ្តល់សំណងសមរម្យឲ្យខ្ញុំសម្រាប់ការបាត់បង់ដីចម្ការ និងផលដំណាំរបស់ខ្ញុំ ដែលឆ្លុយតបទៅនឹងតម្លៃទីផ្សារពិតប្រាកដទេ។ ប្រសិនបើខ្ញុំរុះរើផ្លាស់ចេញទៅ ខ្ញុំនឹងបាត់បង់ប្រាក់ចំណូល ហើយជីវភាពរបស់ខ្ញុំនិងប្រឈមការលំបាក។ យើងនឹងប្រឈមបញ្ហាជាច្រើន ដូចជា ខ្វះស្បៀងអាហារ រឺក៏បាត់បង់ឱកាសប្រើប្រាស់ទន្លេ និងគ្មានទីធ្លាគ្រប់គ្រាន់សម្រាប់ចិញ្ចឹមសត្វ*"។[50] ស្ត្រីម្នាក់ទៀតមកពីភូមិស្រែគរ និយាយថា "*ខ្ញុំមិនចង់ចាកចេញពីផ្ទះទៅនៅលើដីដែលធ្វើកសិកម្មមិនល្អនោះទេ។ ផ្ទះថ្មី និងដីកសិកម្មដែលគេផ្តល់ឲ្យនោះមានទំហំតូចណាស់*"។[51]

អ្នកភូមិក៏បាន លើកឡើងពីការព្រួយបារម្ភច្រើនអំពីកង្វះតម្លាភាព នៅក្នុងដំណើរការនៃការស្រង់ទិន្នន័យ ដោយមានស្ត្រីអាយុ៤៥ឆ្នាំម្នាក់មកពីភូមិច្រូបបញ្ជាក់ថា "*ផែនការសំណងមិនច្បាស់លាស់ ឬគ្មានតម្លាភាពឡើយ ហើយខ្ញុំមិនយល់ស្របនឹងសកម្មភាពដែលកំពុងអនុវត្តដោយក្រុមហ៊ុននោះទេ។ ខ្ញុំនឹងតស៊ូរហូតដល់ខ្ញុំស្លាប់ ខ្ញុំមិនចាកចេញពីផ្ទះរបស់ខ្ញុំ ទៅនៅកន្លែងថ្មីទេ*"។[52] ស្ត្រីម្នាក់ទៀតមកពីភូមិស្រែគរ និយាយថា "*ខ្ញុំមិនជឿថា ក្រុមហ៊ុននឹងផ្តល់សំណងត្រឹមត្រូវឱ្យយើងនោះឡើយ។ ខ្ញុំសូមអំពាវនាវទៅក្រុមហ៊ុនទំនប់វារីអគ្គិសនីសូមបញ្ឈប់ការសាងសង់ និងបញ្ឈប់ធ្វើឱ្យជីវិតរបស់យើងកាន់តែលំបាក*"។[53]

ទីបំផុត មានការយល់ដឹងយ៉ាងច្បាស់ ក្នុងចំណោមប្រជាសហគមន៍ថា ការចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យ និងការផ្តិតមេដៃលើឯកសារស្រង់ទិន្នន័យនេះ គឺមានន័យថា ពួកគាត់បានចុះហត្ថលេខាយល់ព្រមបោះបង់សិទ្ធិដែលពួកគាត់មានលើដីធ្លីរបស់ពួកគាត់។ អ្នកឆ្លើយតបម្នាក់បានពន្យល់ពីមូលហេតុដែលមិនបានចូលរួមនៅក្នុងសម្រង់ស្ថិតិទ្រព្យសម្បត្តិ ដោយនិយាយថា "*គេសួរខ្ញុំថា តើខ្ញុំនឹងធ្វើអ្វីនៅពេលដែលផ្ទះរបស់ខ្ញុំត្រូវទឹកលិច ប៉ុន្តែខ្ញុំដឹងថា ប្រសិនបើខ្ញុំព្រមផ្តិតមេដៃនោះមានន័យថាខ្ញុំប្រគល់ដីរបស់ខ្ញុំឲ្យទៅក្រុមហ៊ុន ខ្ញុំមិនចង់រុះរើចេញពីទីនេះទេ។ ខ្ញុំមិនបានធ្វើអ្វីខុស ឬប្រឆាំងនឹងច្បាប់ឡើយ ខ្ញុំមានសិទ្ធិ*"។[54]

## V. **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

លទ្ធផលដែលបានរកឃើញពីកម្រងសំណួរសហគមន៍ បានបង្ហាញថា មានបញ្ហាជាប្រព័ន្ធដែលកើតឡើងជាទូទៅពាក់ព័ន្ធនឹងរបៀបចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនោះ។ លទ្ធផលនេះបង្ហាញថាក្នុងករណីជាច្រើន សិទ្ធិរបស់ប្រជាសហគមន៍ដែលត្រូវទទួលបានព័ត៌មាន និងការពិគ្រោះយោបល់គ្រប់គ្រាន់ក្នុងដំណើរការនៃការស្រង់ទិន្នន័យ មិនត្រូវបានគោរពឡើយ។

លទ្ធផលនេះបង្ហាញថា ចំនួនប្រជាពលរដ្ឋដ៏ច្រើនគួរអោយកត់សម្គាល់ដែលបានយល់ព្រម

50 បញ្ជីសំណួរទី២៤។

51 បញ្ជីសំណួរទី៩៨។

52 បញ្ជីសំណួរទី១៦០។

53 បញ្ជីសំណួរទី១០១។

54 បញ្ជីសំណួរទី១២១។

ចូលរួមក្នុងដំណើរការនៃការស្រង់ទិន្នន័យទ្រព្យសម្បត្តិនេះ ដោយពុំត្រូវបានជូនដំណឹង និងផ្តល់សេរីភាពក្នុងការសម្រេចចិត្តឡើយ។ ផ្ទុយទៅវិញ មានភស្តុតាងរឹងមាំដែលបញ្ជាក់ថា អ្នកភូមិត្រូវគេបង្ខិតបង្ខំឱ្យចូលរួម ទោះដោយផ្ទាល់ឬដោយប្រយោល ក្នុងដំណើរការនៃការស្រង់ទិន្នន័យនោះ ទាំងពួកគាត់មិនយល់ច្បាស់ និងមិនសូវមានជំនឿចិត្ត ដូច្នេះហើយពួកគាត់បានធ្វើដូច្នេះដោយការបង្ខិតបង្ខំ។ រឿងនេះធ្វើឲ្យមានមន្ទិលសង្ស័យយ៉ាងខ្លាំង ទៅលើភាពស្របច្បាប់នៃដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិនេះ។ ប្រសិនបើ ឯកសារស្រង់ទិន្នន័យទាំងអស់ដែលអ្នកភូមិបានផ្តិតមេដៃនោះត្រូវបានយកទៅរៀបចំជាកិច្ចសន្យាដោយគណៈកម្មការផ្តល់សំណង និងការតាំងទីលំនៅថ្មី និងក្រុមហ៊ុនអភិវឌ្ឍន៍គម្រោងក្នុងស្ថានភាពដែលមានស្នាមមេដៃជាច្រើនរបស់ប្រជាពលរដ្ឋនៅលើឯកសារនោះ ហាក់ដូចបង្ហាញនូវការរំលោភលើលក្ខខណ្ឌតម្រូវនៃច្បាប់កម្ពុជាស្តីពីកិច្ចសន្យា។[55] តាមច្បាប់នេះកិច្ចព្រមព្រៀងកិច្ចសន្យាគ្មានសុពលភាពទេ កាលណាលទ្ធផលមិនបានមកពីការព្រមព្រៀងពិតប្រាកដ និងដោយគ្មានការបង្ខិតបង្ខំ ឬមានពាក់ព័ន្ធព័ត៌មានខុស ឬមានការអនុវត្តការបង្ខិតបង្ខំ ឬមានការបកស្រាយមិនត្រូវដើម្បីធ្វើឲ្យទទួលបានកិច្ចព្រមព្រៀង។[56]

របាយការណ៍នេះ សូមផ្តល់អនុសាសន៍ដូចខាងក្រោម ដោយផ្អែកលើមូលដ្ឋាននៃលទ្ធផលពីការរកឃើញទាំងនេះ៖

- ដោយសាររបាយការណ៍នានាដែលមានភាពស៊ីសង្វាក់គ្នា និងកើតឡើងនៅកន្លែងជាច្រើនអំពីការភ័យខ្លាច និងការបំភិតបំភ័យ ក្នុងចំណោមប្រជាសហគមន៍ ក្នុងអំឡុងពេលនៃដំណើរការចុះស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ឯកសារ ឬកិច្ចសន្យាផ្សេងៗ ដែលកើតចេញពីលទ្ធផលនៃដំណើរការនេះគួរគប្បីចាត់ទុកថាគ្មានសុពលភាព។
- រាល់សកម្មភាពដែលទាក់ទងទៅនឹងផែនការផ្តល់សំណង និងការតាំងលំនៅថ្មីនេះ គប្បីត្រូវផ្អាកជាបន្ទាន់ រហូតដល់មានការស៊ើបអង្កេតពេញលេញ និងឯករាជ្យទៅលើកំហុសឆ្គងដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ។
- ដោយសារជាក់ស្តែង ប្រជាសហគមន៍ភាគច្រើននៅតែបដិសេធមិនព្រមចូលរួមនៅក្នុងដំណើរការនៃការស្រង់ទិន្នន័យនេះ ដូច្នេះដំណើរការនៃការតាំងទីលំនៅថ្មី គប្បីត្រូវបញ្ឈប់ រង់ចាំរហូតទទួលបានការយល់ព្រមពីប្រជាសហគមន៍ទាំងអស់ដែលរងផលប៉ះពាល់។
- ការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ គប្បីត្រូវធ្វើឡើងវិញ ដោយមានកិច្ចប្រឹងប្រែងពិតប្រាកដដើម្បីធានាថា៖

55 សូមមើលត្រង់ជំពូកទី២ នៃក្រមរដ្ឋប្បវេណី ដែលបានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីខែមិថុនា ឆ្នាំ២០០៣

56 សូមមើលមាត្រាទី៣៤៥-៣៥០ ត្រង់ផ្នែកទី២ នៃឯកសារយោងដូចគ្នាខាងលើ

(1) មានសេចក្តីជូនដំណឹងគ្រប់គ្រាន់ទៅសហគមន៍ និងព័ត៌មានលម្អិតអំពីដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ និងគោលនយោបាយផ្តល់សំណង។

(2) មានការផ្តល់ឱកាសដែលមានន័យពិតប្រាកដដើម្បីផ្តល់គំនិត និងស្រេបទៅនីតិនៃការតាំងទីលំនៅថ្មី។

(3) មានវិធានការដើម្បីការពារប្រជាសហគមន៍ពីការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ទោះដោយផ្ទាល់និងដោយប្រយោល នៅក្នុងដំណើរការនោះ។

(4) មានបញ្ចូលអ្នកភូមិដែលរងគ្រោះទាំងអស់ រួមទាំងអ្នកដែលនៅភូមិក្លែកដែលបាន (ឬដែលនឹង) បាត់បង់ដីធ្លី និងទ្រព្យសម្បត្តិ។

(5) ការគោរពតាមកាតព្វកិច្ចយ៉ាងពេញលេញទៅតាមច្បាប់របស់ប្រទេសកម្ពុជា និងកាតព្វកិច្ចនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងការស្រង់ទិន្នន័យទ្រព្យសម្បត្តិ និងការតាំងទីលំនៅថ្មី។

• មានអនុវត្តវិធានការដើម្បីធានាថា ប្រជាសហគមន៍យល់យ៉ាងច្បាស់អំពីគោលនយោបាយស្តីពីការផ្តល់សំណង និងឯកសារស្រង់ទិន្នន័យ ប្រជាសហគមន៍យល់ព្រមដោយគ្មានការបង្ខិតបង្ខំ និងផ្តល់ជូនពួកគាត់នូវឯកសារដែលជាលទ្ធផលនៃការស្រង់ទិន្នន័យ។

• គណៈកម្មការដោះស្រាយសំណងផលប៉ះពាល់ (Compensation Resolution Committee) ត្រូវជួយសម្រួលដល់សិទ្ធិនៃដំណើរការដាក់ពាក្យបណ្តឹងប្រកបដោយយុត្តិធម៌ និងមានតម្លាភាព ដើម្បីឲ្យបញ្ហាណាមួយដែលកើតឡើងក្នុងអំឡុងពេលចុះអនុវត្តដំណើរការនៃការស្រង់ទិន្នន័យអំពីទ្រព្យសម្បត្តិ ឬការតាំងទីលំនៅថ្មីអាចត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព។

# ឯកសារយោង


International Rivers (2015) . Lower sesan 2 dam. Available at: www.internationalrivers.org/campaigns/lower-sesan-2-dam

Mekong Watch. (November 5, 2015). Lower Sesan 2 Dam: Compensation and resettlement program implementation impacts on indigenous communities. Available at: www.mekongwatch.org/PDF/LS2_NotesCompensationResettlement.pdf

Rivers Coalition of Cambodia. (August 19, 2009). Proposed lower sesan 2 dam, Cambodia fails to uphold best practice. Available at: www.internationalrivers.org/resources/proposed-lower-sesan-2-dam-cambodia-fails-to-uphold-best-practice-3787

Ian Baird. (May 2009). Best practices in compensation and resettlement for large dams. The case of the planned lower sesan 2 hydropower project in northeastern Cambodia' Rivers Coalition in Cambodia. Available at: www.3spn.org/wp-content/uploads/2012/01/Baird-2009-Compensation-and-Resettlement-EN.pdf

Mekong Commons. (August 23 2015). Lower Sesan 2: Construction resumed, troubles restarted. Available at: www.mekongcommons.org/lower-sesan-2-construction-resumed-trobles-restarted

Key Consultants (Cambodia) Ltd., *Environment Impact Assessment for Feasibility Study of Lower Sesan 2 Hydropower Project.*

Key Consultants (Cambodia) Ltd. (KCC), Phnom Penh, October 2008; *Executive Summary*, page 6.

Mekong Watch. (June 2015). *Interview at affected villages in February 2015 regarding asset measurement survey held on lower sesan 2 dam.* Available at: www.mekongwatch.org/PDF/LS2_FieldNoteRegardingAssetSurvey.pdf

Mekong Watch. (October 10, 2014). *Informal notes from interview with affected villagers in Phluk.* Mekong Watch.

Civil Code of Cambodia, submitted to the Council of Ministers June 2003: Book Four, Chapter Two.

FACT
Sustainable Livelihoods

CRITICAL ECOSYSTEM PARTNERSHIP FUND

# DROWNING DISSENT
# REPORT ON THE EXPERIENCES OF COMMUNITIES TO BE RESETTLED FOR THE LOWER SESAN 2 DAM





## Findings and Recommendations on the Asset Survey



TONLE SAP LAKE WATERKEEPER

The Coalition of Cambodia Fishers (CCF)

MY VILLAGE

3S Rivers Protection Network

Culture and Environment Preservation Association CEPA

July 2016

# DROWNING DISSENT

# REPORT ON THE EXPERIENCES OF COMMUNITIES TO BE RESETTLED FOR THE LOWER SESAN 2 DAM

